**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរអគ្គិសនីកម្ពុជា**

លេខ : ០៤៩-០៦-អអក ភ្នំពេញ, ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៦

# សេចក្តីសម្រេច

## ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា

- បានឃើញច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាលេខ នស/រកត/១១០៤/០២២ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការតែងតាំង **ឯកឧត្តម ទី នរិទ្ធ** ជាប្រធាននៃអាជ្ញាធរអគ្គិសនីកម្ពុជា
- បានឃើញសេចក្តីសម្រេចលេខ ០៧៨ សរ-០៦ អអក ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលមាត្រា ១២ និងមាត្រា ២៤ នៃបទបញ្ញាផ្ទៃក្នុងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា
- ពិនិត្យសំណូមពរការងារចាំបាច់របស់អាជ្ញាធរអគ្គិសនីកម្ពុជា

### សម្រេចឱ្យប្រើ

បទបញ្ញាផ្ទៃក្នុងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ដែលបានកែសម្រួលមាត្រា ១២ ជំពូកទី២ នៅសម័យប្រជុំលើកទី៧៦ នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៦ និងកែសម្រួលមាត្រា ២៤ ជំពូកទី៦ នៅសម័យប្រជុំលើកទី៦៩ នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៦ របស់អាជ្ញាធរអគ្គិសនីកម្ពុជា មានខ្លឹមសារទាំងស្រុងដូចតទៅ :

# បទបញ្ជាផ្ទៃក្នុងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

ꕥꕥꕥ

## ជំពូកទី ១
## អំពីឈ្មោះស្ថាប័ន ភារកិច្ច និងទីស្នាក់ការ

**មាត្រា ១.- ឈ្មោះស្ថាប័ន**

យោងតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្រកាសឱ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស-រកម-០២០១-០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ ស្ថាប័ននេះមានឈ្មោះថា "**អាជ្ញាធរអគ្គិសនីកម្ពុជា**" សរសេរកាត់ "**អ.អ.ក**" ។

នៅក្នុងបទបញ្ជាផ្ទៃក្នុងនេះ ពាក្យថា **អាជ្ញាធរអគ្គិសនីកម្ពុជា** សំដៅស្ថាប័នអាជ្ញាធរអគ្គិសនីកម្ពុជា ដោយឡែកពាក្យថា **អាជ្ញាធរ** សំដៅសមាជិកអាជ្ញាធរទាំងអស់រាប់ទាំងប្រធាន ។

**មាត្រា ២.- ភារកិច្ចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា**

អាជ្ញាធរអគ្គិសនីកម្ពុជាជាអ្នកគ្រប់គ្រងសកម្មភាពនៃការធ្វើសេវាកម្ម និងការប្រើប្រាស់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ អាជ្ញាធរអគ្គិសនីកម្ពុជាមានសមត្ថកិច្ចចេញ ដកហូត ឬព្យួរអាជ្ញាប័ណ្ណសម្រាប់ការធ្វើសេវាកម្មអគ្គិសនី ព្រមទាំងជាអ្នកកំណត់ថ្លៃសេវា ចេញនូវបញ្ញត្តិ ធ្វើការត្រួតពិនិត្យ ដាក់ពិន័យ និងដោះស្រាយវិវាទពាក់ព័ន្ធនឹងការផ្តល់សេវាកម្មនិងការប្រើប្រាស់អគ្គិសនីដើម្បីធានាឱ្យការផ្តល់សេវាកម្មអគ្គិសនី និងការប្រើប្រាស់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជាប្រព្រឹត្តទៅដោយប្រសិទ្ធភាព គុណភាព ចីរភាព និងតម្លាភាព ។

**មាត្រា ៣.- ទីស្នាក់ការរបស់អាជ្ញាធរអគ្គិសនីកម្ពុជា**

ទីចាត់ការកណ្តាលរបស់អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវតាំងនៅរាជធានីភ្នំពេញ ។

អនុលោមតាមការរីកចម្រើននៃវិស័យអគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា បើសេវាកម្មនិងការប្រើប្រាស់អគ្គិសនីនៅតាមបណ្តាខេត្តណាមួយមានទំហំធំសមល្មម ដែលអាជ្ញាធរអគ្គិសនីកម្ពុជាយល់ឃើញថាត្រូវមានការិយាល័យសាខាមួយដើម្បីធានាបាននូវការអនុវត្តការងាររបស់ខ្លួន សម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជាអាចសម្រេចឱ្យមានការិយាល័យសាខារបស់អាជ្ញាធរអគ្គិសនីកម្ពុជា នៅតាមបណ្តាខេត្តនោះ ។

# ជំពូកទី ២
# អំពីសម័យប្រជុំរបស់អាជ្ញាធរ

## មាត្រា ៤.- សម័យប្រជុំរបស់អាជ្ញាធរ

អាជ្ញាធរអគ្គិសនីកម្ពុជាសម្រេចនិងអនុម័តបញ្ហាគន្លឹះសំខាន់ៗ តាមរយៈការពិភាក្សា និងការបោះឆ្នោតនៅក្នុងសម័យប្រជុំ ដូច្នេះ **សម័យប្រជុំរបស់អាជ្ញាធរ** (ឬហៅកាត់ថា **សម័យប្រជុំ**) គឺជាសមត្ថកិច្ចសម្រេចការងារខ្ពស់បំផុតរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ។ យោងតាមមាត្រា២១នៃច្បាប់ស្ដីពីអគ្គិសនី សមាជិកអាជ្ញាធរទាំងអស់ត្រូវមានសំឡេងក្នុងការបោះឆ្នោតអនុម័តលើរាល់បញ្ហា ដែលតម្រូវឱ្យមានការអនុម័តពីអាជ្ញាធរអគ្គិសនីកម្ពុជា ។ ការអនុម័តនេះត្រូវផ្អែកលើសំឡេងភាគច្រើន មានន័យថាយ៉ាងតិចបំផុតមានសំឡេងគាំទ្រ ២សំឡេង។ សម័យប្រជុំរបស់អាជ្ញាធរអាចយកជាការបាន លុះត្រាតែមានវត្តមាន **សមាជិកសម័យប្រជុំ** ពីររូបឡើងទៅ ។

**សមាជិកសម័យប្រជុំ** នៅក្នុងបទបញ្ញាផ្ទៃក្នុងនេះ សំដៅតែប្រធាននិងសមាជិកអាជ្ញាធរដែលត្រូវចូលរួមក្នុងសម័យប្រជុំរបស់អាជ្ញាធរ និងមានសិទ្ធិបោះឆ្នោតអនុម័តលើបញ្ហាតែប៉ុណ្ណោះ ពុំសំដៅលើមន្ត្រីអ្នកជំនាញរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ឬអ្នកពាក់ព័ន្ធ ឬសាធារណជនឡើយ។ មន្ត្រី អ្នកជំនាញ អ្នកពាក់ព័ន្ធ ឬសាធារណជន ដែលត្រូវបានអញ្ជើញឱ្យចូលរួមក្នុងសម័យប្រជុំ ត្រូវបានហៅថា **អ្នកចូលរួម** ។

## មាត្រា ៥.- រូបភាពនៃសម័យប្រជុំ

សម័យប្រជុំអាចធ្វើឡើងតាមរូបភាព ៣ គឺ :

**១-សម័យប្រជុំជាសាធារណៈ** - ជាសម័យប្រជុំដែលបើកចំហឱ្យសាធារណជនចូលស្ដាប់ដោយសេរី

**២-សម័យប្រជុំមិនសាធារណៈ** - ជាសម័យប្រជុំដែលចូលរួមតែអាជ្ញាធរ មន្ត្រីជំនាញរបស់អាជ្ញាធរអគ្គិសនីកម្ពុជា និងអាចអញ្ជើញអ្នកពាក់ព័ន្ធនឹងបញ្ហាឱ្យចូលរួម

**៣-សម័យប្រជុំសម្ងាត់** - ជាសម័យប្រជុំដែលអាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវលាក់ការណ៍សម្ងាត់អ្វីមួយ សម័យប្រជុំនេះមានការចូលរួមតែអាជ្ញាធរ និងនាយកប្រតិបត្តិ ប៉ុណ្ណោះ ។

រូបភាពនៃសម័យប្រជុំនិមួយៗ ត្រូវសម្រេចដោយប្រធានអាជ្ញាធរ ស្របតាមនីតិវិធីនៃបញ្ហានីមួយៗ ។

## មាត្រា ៦.- ការកោះអញ្ជើញសម័យប្រជុំ

សម័យប្រជុំត្រូវកោះអញ្ជើញដោយប្រធានអាជ្ញាធរ ឬដោយអ្នកជំនួសក្នុងករណីអវត្តមានរបស់ប្រធាន ។ សម័យប្រជុំអាចធ្វើបាននៅគ្រប់ទីកន្លែងតាមការចាំបាច់ ។

ក្នុងករណីដែលប្រធានអាជ្ញាធរអវត្តមាន និងពុំមានការចាត់តាំងអ្នកជំនួស សមាជិក២រូបទៀត អាចកោះអញ្ជើញសម័យប្រជុំបាន ។

លិខិតអញ្ជើញប្រជុំត្រូវចុះហត្ថលេខាដោយប្រធានអាជ្ញាធរ ឬអ្នកជំនួស ។ លិខិតអញ្ជើញព្រមទាំងឯកសារផ្សេងៗទៀតសម្រាប់ប្រជុំត្រូវប្រគល់ជូនសមាជិកសម័យប្រជុំ ឱ្យបានមុនថ្ងៃប្រជុំក្នុងរយៈពេលយ៉ាងតិច៣ថ្ងៃការងារ លើកលែងតែក្នុងករណីចាំបាច់ពិសេសដែលតម្រូវឱ្យមានការសម្រេចបន្ទាន់ភ្លាមៗ។

## មាត្រា ៧.- របៀបវារៈសម័យប្រជុំ

របៀបវារៈសម័យប្រជុំត្រូវសម្រេចដោយប្រធានអាជ្ញាធរ ឬអ្នកជំនួស បន្ទាប់ពីបានរៀបចំ និងដាក់ជូនអាជ្ញាធរដោយនាយកប្រតិបត្តិ ។ របៀបវារៈនេះព្រមទាំងឯកសារអមផ្សេងៗទៀតត្រូវផ្ញើជូនសមាជិកសម័យប្រជុំជាមួយលិខិតអញ្ជើញ ។

ប្រធានអាជ្ញាធរអាចសម្រេចឱ្យផ្សព្វផ្សាយរបៀបវារៈសម័យប្រជុំ លើកលែងតែក្នុងករណីចាំបាច់ដែលអាជ្ញាធរត្រូវលាក់ការណ៍សម្ងាត់ ។

សមាជិកអាជ្ញាធរអាចលើកបញ្ហាណាមួយដាក់ចូលរបៀបវារៈសម័យប្រជុំបាន ប៉ុន្តែត្រូវធ្វើសំណើទៅប្រធានអាជ្ញាធរឱ្យបានមុនយ៉ាងតិច ១ (មួយ) អាទិត្យ មុនពេលប្រធានអាជ្ញាធរសម្រេចលើរបៀបវារៈ ។ ប្រធានអាជ្ញាធរត្រូវចារលើលិខិតស្នើនូវថ្ងៃទទួលលិខិតនេះ ។ ក្នុងករណីដែលសំណើនេះមានលក្ខណៈគ្រប់គ្រាន់ហើយ ប៉ុន្តែពុំត្រូវបានដាក់ចូលក្នុងរបៀបវារៈសម័យប្រជុំដែលស្នើសុំ ប្រធានអាជ្ញាធរត្រូវចាត់ចែងដាក់ចូលជាបញ្ហាអាទិភាពនៅសម័យប្រជុំបន្ទាប់ ។ បើសិនជាសំណើនេះពុំទាន់មានឯកសារឬពុំមានគ្រប់គ្រាន់សម្រាប់សម័យប្រជុំសម្រេចទេ ប៉ុន្តែមានការទាមទាររបស់សមាជិកដែលដាក់សំណើ ប្រធានអាជ្ញាធរអាចកោះហៅការពិគ្រោះយោបល់ផ្ទៃក្នុងមួយក្នុងរង្វង់សមាជិកអាជ្ញាធរមុននឹងធ្វើការសម្រេចចិត្ត ។

## មាត្រា ៨.- ប្រធានសម័យប្រជុំ

ប្រធានអាជ្ញាធរគឺជាប្រធានសម័យប្រជុំ និងជាអ្នកដឹកនាំដំណើរការនៃសម័យប្រជុំ ។ ប្រធានអាជ្ញាធរអាចចាត់តាំងសមាជិកណាមួយឱ្យធ្វើជាប្រធានស្ដីទីជំនួសខ្លួនក្នុងរយៈពេលដែលខ្លួនអវត្តមាន ។

ក្នុងករណីដែលប្រធានអវត្តមាន និងពុំមានការចាត់តាំងអ្នកជំនួស សមាជិកដែលអាយុច្រើនជាងគេត្រូវធ្វើជាប្រធានសម័យប្រជុំ និងដឹកនាំសម័យប្រជុំ ។

## មាត្រា ៩.- ការកំណត់រូបភាពសម័យប្រជុំ

សម័យប្រជុំសម្រាប់សម្រុះសម្រួលពាក្យបណ្ដឹងតវ៉ាត្រូវធ្វើឡើងជាសាធារណៈ ។ សេចក្ដីសម្រេចដោយភ្ជាប់នឹងមូលហេតុរបស់អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវប្រកាសជាសាធារណៈភ្លាម លើកលែង

តែមានមូលហេតុណាមួយដែលអាផ្គាធរសម្រេចពន្យារការប្រកាសមួយរយៈសិន ។ រាល់សេចក្តីសម្រេចការសន្និដ្ឋាន កំណត់ហេតុ និងសំណុំរឿងផ្សេងៗនៃសម័យប្រជុំសម្រាប់សម្រុះសម្រួលពាក្យបណ្តឹងតវ៉ាត្រូវមានដាក់ជូនសាធារណជនពិនិត្យដោយសេរីក្នុងការិយាល័យរបស់អាផ្គាធរអគ្គិសនីកម្ពុជា ។ ប្រធានសម័យប្រជុំត្រូវចេញបញ្ជា ដើម្បីរក្សាការសម្ងាត់ណាដែលអាផ្គាធរអគ្គិសនីកម្ពុជាបានទទួលឱ្យនៅតែរក្សាភាពសម្ងាត់ដដែល បើសិនជាមានសមាជិកសម័យប្រជុំណាមួយបានស្នើសុំឱ្យរក្សាពត៌មាននោះទុកជាការសម្ងាត់ដោយមានមូលហេតុចាំបាច់ ។ ការសម្ងាត់នេះត្រូវការពារដោយច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ២២ ។

ចំពោះសម័យប្រជុំសម្រាប់ពិភាក្សា និងអនុម័តនូវបទបញ្ជា វិធាន នីតិវិធី បទប្បញ្ញត្តិណាមួយ ឬក៏បញ្ហាអ្វីផ្សេងៗទៀត បើសិនជាគ្មាននីតិវិធីកំណត់ច្បាស់លាស់ទេ ប្រធានអាផ្គាធរអាចសម្រេចឱ្យអនុវត្តការប្រជុំជាសម័យប្រជុំសាធារណៈ ឬមិនសាធារណៈ ។ ក្នុងពេលប្រជុំដែលបានកំណត់ធ្វើជាសាធារណៈ បើសិនជាមានការស្នើសុំពីសមាជិក២(ពីរ)រូបឱ្យរក្សាការសម្ងាត់ផ្នែកណាមួយ ឬទាំងអស់នៃរបៀបវារៈរបស់សម័យប្រជុំ ប្រធានសម័យប្រជុំអាចធ្វើការសម្រេចឱ្យការប្រជុំផ្នែកនោះ ឬទាំងអស់បិតនៅក្នុងភាពសម្ងាត់ ។ ការសម្ងាត់នេះត្រូវការពារដោយច្បាប់ ។

### មាត្រា ១០ៈ ការរៀបចំសម័យប្រជុំ

ដើម្បីបើកសម័យប្រជុំ លេខាធិការដ្ឋានរបស់អាផ្គាធរអគ្គិសនីកម្ពុជាត្រូវរៀបចំនូវការងារចាំបាច់មួយចំនួនដូចខាងក្រោម ៖

១- រៀបចំរបៀបវារៈសម័យប្រជុំ

២- រៀបចំឯកសារពាក់ព័ន្ធផ្សេងៗ ស្របតាមការកំណត់របស់នីតិវិធីក្នុងការដោះស្រាយបញ្ហានីមួយៗ

៣- រៀបចំបញ្ជីឈ្មោះអ្នកដែលត្រូវចូលរួមក្នុងសម័យប្រជុំ តាមរូបភាពសម័យប្រជុំដែលបានកំណត់ ។ ក្នុងករណីសម័យប្រជុំជាសម័យប្រជុំសាធារណៈ ត្រូវធ្វើបញ្ជីតែសមាជិក និងមន្ត្រីអាផ្គាធរ ព្រមទាំងអ្នកពាក់ព័ន្ធដែលគ្រោងអញ្ជើញចូលរួមប៉ុណ្ណោះ ។

៤- ចាត់តាំងមន្ត្រីដែលត្រូវធ្វើជាលេខាសម័យប្រជុំ ។

៥- ចាត់តាំងមន្ត្រីជំនាញរបស់លេខាធិការដ្ឋានដែលត្រូវធ្វើរបាយការណ៍ និងបំភ្លឺឱ្យអាផ្គាធរសម្រាប់របៀបវារៈនីមួយៗ ។

៦- កំណត់ទីកន្លែងដែលត្រូវធ្វើសម័យប្រជុំ ។

ការងារខាងលើនេះ ត្រូវស្នើសុំការសម្រេចពីប្រធានអាផ្គាធរ ។

## មាត្រា ១១_ ដំណើរការសម័យប្រជុំ

សម័យប្រជុំត្រូវបើកដោយការប្រកាសពីកូរ៉ុម ប្រកាសពីរបៀបវារៈ និងការប្រកាសបើកដោយប្រធានសម័យប្រជុំ ។ ក្នុងពេលប្រជុំនីមួយៗ លេខាសម័យប្រជុំស្រង់ឈ្មោះសមាជិកដែលអវត្តមានដោយបញ្ជាក់ពីមូលហេតុនៃអវត្តមាននេះ ។

តាមធម្មតា សម័យប្រជុំត្រូវដំណើរការជាលំដាប់តាមរបៀបវារៈ វៀរលែងតែក្នុងសម័យប្រជុំខ្លះដែលសមាជិកភាគច្រើនបានសម្រេចផ្សេងពីនេះ ។

របៀបវារៈនីមួយៗត្រូវចាប់ផ្ដើមឡើងដោយរបាយការណ៍របស់នាយកដ្ឋានជំនាញ បន្ទាប់មកបន្តដោយការសួរបញ្ជាក់ និងការស្នើសុំបំភ្លឺពីសមាជិកសម័យប្រជុំទៅនាយកដ្ឋានជំនាញ និងអ្នកពាក់ព័ន្ធចុងក្រោយគឺការពិភាក្សា និងការបោះឆ្នោតរបស់សមាជិកសម័យប្រជុំ ។

ការធ្វើរបាយការណ៍ ការសួរបញ្ជាក់ ការស្នើសុំបំភ្លឺ និងការពិភាក្សាលើរបៀបវារៈនីមួយៗត្រូវធ្វើឡើងតាមការដឹកនាំរបស់ប្រធានសម័យប្រជុំ ។ ក្នុងការជជែកពិភាក្សា បើមានយោបល់ផ្សេងគ្នាវាគ្និនត្រូវនិយាយឆ្លាស់គ្នាតាមការអនុញ្ញាតរបស់ប្រធានសម័យប្រជុំ ។ ហាមមិនឱ្យនិយាយកាត់ពាក្យសំដីអ្នកដទៃ មិនឱ្យនិយាយវាយប្រហារលើបុគ្គល មិនឱ្យសំដែងអាការៈផ្សេងៗ ដែលនាំឱ្យខូចសណ្ដាប់ធ្នាប់ ។

កំណត់ហេតុនៃសម័យប្រជុំ ត្រូវចុះហត្ថលេខាដោយប្រធានសម័យប្រជុំ និងផ្ញើជូនសមាជិកចូលរួម ។ កំណត់ហេតុនេះត្រូវមានសម្រាប់ឱ្យសាធារណជនពិនិត្យ នៅការិយាល័យរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ។

ក្នុងសម័យប្រជុំសម្ងាត់ អ្នកចូលរួមត្រូវមានតែសមាជិកសម័យប្រជុំ និងនាយកប្រតិបត្តិប៉ុណ្ណោះ ។ នាយកប្រតិបត្តិត្រូវធ្វើកំណត់ហេតុនៃការប្រជុំនេះ ។ កំណត់ហេតុត្រូវចុះហត្ថលេខាដោយប្រធានសម័យប្រជុំ និងត្រូវផ្ញើជូនតែប្រធាននិងសមាជិកអាជ្ញាធរប៉ុណ្ណោះ ដោយវាយអក្សរ "រក្សាការសម្ងាត់ " ។ កំណត់ហេតុនេះ ត្រូវរក្សាទុកដោយឡែកក្នុងឯកសាររក្សាការសម្ងាត់ ។ ការសម្ងាត់នេះត្រូវការពារដោយច្បាប់ ។

## មាត្រា ១២_ ការឧបត្ថម្ភចំពោះការចូលរួមក្នុងសម័យប្រជុំ និងការពិន័យចំពោះការខកខានមកប្រជុំរបស់សមាជិកសម័យប្រជុំ

### ១- ការឧបត្ថម្ភចំពោះការចូលរួមក្នុងសម័យប្រជុំ

សមាជិកអាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវចូលរួមក្នុងសម័យប្រជុំតាមការកោះអញ្ជើញដោយប្រធានអាជ្ញាធរ ឬដោយអ្នកជំនួសក្នុងករណីអវត្តមានរបស់ប្រធាន ។ សមាជិកអាជ្ញាធរអគ្គិសនីកម្ពុជា ដែលបានចូលរួមក្នុងសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីដោះស្រាយបញ្ហានានាក្នុងការងាររបស់អាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវទទួលបាននូវប្រាក់ឧបត្ថម្ភដូចខាងក្រោម ÷

- ប្រធានសម័យប្រជុំ 400,000៛ (បួនរយពាន់រៀល) ក្នុងការចូលរួមសម័យប្រជុំមួយលើក
- សមាជិកសម័យប្រជុំ 300,000៛ (បីរយពាន់រៀល) ក្នុងការចូលរួមសម័យប្រជុំមួយលើក ។

**២- ការពិន័យចំពោះការខកខានមកប្រជុំរបស់សមាជិកសម័យប្រជុំ**

សមាជិកសម័យប្រជុំមិនអាចអវត្តមាន ដោយមិនមានការអនុញ្ញាតពីប្រធានអាជ្ញាធរបានឡើយ ។ សមាជិកសម័យប្រជុំណាឈប់ខានមកប្រជុំលើសពី២ដង ដោយគ្មានការអនុញ្ញាត ត្រូវកាត់ប្រាក់បៀវត្សចំពោះថ្ងៃអវត្តមាននោះ ។ សមាជិកសម័យប្រជុំណាដែលបានទទួលការអនុញ្ញាតឱ្យឈប់ ហើយឈប់លើសចំនួនថ្ងៃអនុញ្ញាតនោះ ត្រូវកាត់ប្រាក់បៀវត្សចំពោះថ្ងៃដែលឈប់លើសពីការអនុញ្ញាត ។

ប្រសិនបើទទួលលិខិតអញ្ជើញមកប្រជុំ ហើយសមាជិកសម័យប្រជុំខកខានមិនបានមកប្រជុំដោយឥតមានមូលហេតុយកជាការបាន សមាជិកនោះត្រូវទទួលទណ្ឌកម្មខាងវិន័យដូចខាងក្រោម ៖

ក- ការខកខានមកប្រជុំលើសពី ២ដង ត្រូវព្រមាន

ខ- បើទទួលការព្រមានហើយនៅតែមិនចូលប្រជុំនោះ ត្រូវកាត់ប្រាក់បៀវត្សតាមចំនួនថ្ងៃអវត្តមាន

គ- ក្រោយពីការព្រមានទី១ហើយ នៅតែមិនចូលប្រជុំលើសពី២ដងទៀតដោយគ្មានមូលហេតុសមស្រប ប្រធានអាជ្ញាធរអាចចេញសេចក្តីព្រមានចុងក្រោយ

ឃ- បើទទួលបានការព្រមានចុងក្រោយហើយ សមាជិកសម័យប្រជុំនោះនៅតែមិនចូលប្រជុំលើសពី២ដងទៀត សមាជិកនោះអាចត្រូវបានចាត់ទុកថាបោះបង់ការបំពេញភារកិច្ចតាមកថាខ័ណ្ឌទី១០ មាត្រា ១៤ នៃច្បាប់ស្តីពីអគ្គិសនី ។ ក្នុងករណីនេះប្រធានឬអ្នកជំនួសត្រូវធ្វើរបាយការណ៍ជូនទៅនាយករដ្ឋមន្ត្រី ដើម្បីអនុវត្តតាមការកំណត់របស់មាត្រា ១៤ នៃច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៣
## អំពីប្រធានអាជ្ញាធរ

### មាត្រា ១៣. តួនាទីរបស់ប្រធានអាជ្ញាធរ

ប្រធានអាជ្ញាធរគឺជាតំណាងស្របច្បាប់របស់អាជ្ញាធរអគ្គិសនីកម្ពុជា ដែលគ្រប់គ្រងកិច្ចការទាំងអស់របស់អាជ្ញាធរអគ្គិសនីកម្ពុជាស្របតាមច្បាប់ អនុក្រឹត្យ ព្រមទាំងបទបញ្ជាផ្ទៃក្នុងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា និងជាអ្នកចុះហត្ថលេខាលើរាល់សេចក្តីសម្រេចរបស់អាជ្ញាធរ ។ ប្រធានអាជ្ញាធរអាចចាត់តាំងសមាជិកអាជ្ញាធរណាមួយផ្សេងទៀតជាលាយលក្ខណ៍អក្សរ ដើម្បីបំពេញភារកិច្ចជាប្រធានស្តីទីក្នុងពេលអវត្តមានរបស់ខ្លួន ។

**មាត្រា ១៤. ការបំពេញការងាររបស់ប្រធានអាជ្ញាធរ**

ប្រធានអាជ្ញាធរត្រូវធ្វើការពេញម៉ោងនៅក្នុងអាជ្ញាធរអគ្គិសនីកម្ពុជា និងមិនត្រូវធ្វើការងារផ្សេងទៀត ឬយល់ព្រមទទួលកម្រៃពីសកម្មភាពផ្សេងៗទៀតបានឡើយ ។

**មាត្រា ១៥. សិទ្ធិអំណាចរបស់ប្រធានអាជ្ញាធរ**

អនុលោមតាមមាត្រា១៨នៃច្បាប់ស្តីពីអគ្គិសនី ប្រធានអាជ្ញាធរមានសិទ្ធិអំណាចគ្រប់គ្រងអាជ្ញាធរអគ្គិសនីកម្ពុជា ដឹកនាំការប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ព្រមទាំងធានាផ្សព្វផ្សាយ និងអនុវត្តរាល់សេចក្តីសម្រេចរបស់សម័យប្រជុំ ។ ប្រធានអាជ្ញាធរអាចមានសិទ្ធិអំណាចបន្ថែមផ្សេងទៀត ដូចជាការសម្រេចលើកិច្ចការប្រចាំថ្ងៃក្នុងនាមជាប្រធានស្ថាប័ន លើកលែងតែភារកិច្ចចំនួន៥ដែលត្រូវតែសម្រេចដោយសម័យប្រជុំរបស់អាជ្ញាធរដាច់ខាតគឺ ១-ការចេញ ការបដិសេធន៍ ការកែប្រែ ឬការលប់ចោលអាជ្ញាប័ណ្ណ ២-ការច្រានចោលពាក្យសុំអាជ្ញាប័ណ្ណ ឬពាក្យសុំកែសម្រួលអាជ្ញាប័ណ្ណ ៣-ការកំណត់ការអនុម័ត ការបដិសេធន៍ ឬការកែប្រែថ្លៃ ឬកម្មវិធីវិនិយោគនិងកម្មវិធីទទួលអគ្គិសនី ៤-ការចេញការកែប្រែ ឬការលុបចោលបទប្បញ្ញត្តិនានារបស់អាជ្ញាធរអគ្គិសនីកម្ពុជា និង ៥-ការសម្រេចសេចក្តីលើពាក្យបណ្តឹងតវ៉ារបស់សាធារណជន ។

អនុលោមតាមមាត្រា១៩នៃច្បាប់ស្តីពីអគ្គិសនី ប្រធានអាជ្ញាធរមានសិទ្ធិតែងតាំងមន្ត្រីទាំងអស់នៅក្រោមឱវាទ និងអាចជួលអ្នកឯកទេសផ្សេងៗទៀតតាមតម្រូវការចាំបាច់សម្រាប់អនុវត្តភារកិច្ចរបស់អាជ្ញាធរអគ្គិសនីកម្ពុជាឱ្យបានត្រឹមត្រូវ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសមាជិកឯទៀត ។ ការពិគ្រោះយោបល់អាចធ្វើឡើងតាមរបៀបប្រជុំពិភាក្សាគ្នាផ្ទាល់ក្រៅពីសម័យប្រជុំផ្លូវការ ឬអាចជាការផ្តល់យោបល់តាមរយៈលិខិតកំណត់បង្ហាញ ។

## ជំពូកទី ៤
## អំពីសមាជិកអាជ្ញាធរ

**មាត្រា ១៦. តួនាទីរបស់សមាជិកអាជ្ញាធរ**

អនុលោមតាមមាត្រា២១នៃច្បាប់ស្តីពីអគ្គិសនី សមាជិកទាំងអស់របស់អាជ្ញាធររាប់ទាំងប្រធានអាជ្ញាធរផងមានសិទ្ធិផ្តល់សំឡេងឆ្នោតដើម្បីសម្រេចលើរាល់បញ្ហាដែលតម្រូវឱ្យមានការអនុម័ត ឬសម្រេចពីអាជ្ញាធរអគ្គិសនីកម្ពុជា តាមរយៈសម័យប្រជុំ និងការបោះឆ្នោត ។

**មាត្រា ១៧. ការបំពេញការងាររបស់សមាជិកអាជ្ញាធរ**

សមាជិកអាជ្ញាធរត្រូវធ្វើការពេញម៉ោងនៅក្នុងអាជ្ញាធរអគ្គិសនីកម្ពុជា និងមិនត្រូវធ្វើការងារផ្សេងទៀត ឬយល់ព្រមទទួលកម្រៃពីសកម្មភាពផ្សេងៗទៀតបានឡើយ ។

**មាត្រា ១៨. ភារកិច្ចផ្សេងទៀតរបស់សមាជិកអាជ្ញាធរ**

ប្រធានអាជ្ញាធរ ត្រូវ ប្រគល់ភារកិច្ច គ្រប់ គ្រងណាមួយក្នុងការងារ ប្រចាំថ្ងៃ របស់អាជ្ញាធរអគ្គិសនីកម្ពុជា ឱ្យសមាជិក២រូបទៀតនៃអាជ្ញាធរ ស្របទៅតាមជំនាញរបស់សមាជិកនោះបន្ថែមពីលើកាតព្វកិច្ចជាសមាជិកអាជ្ញាធរ ដែលមានភារកិច្ចចូលរួម និងបោះឆ្នោតអនុម័តលើបញ្ហាផ្សេងៗក្នុងសម័យ ប្រជុំរបស់អាជ្ញាធរ ។ ក្នុងការ គ្រប់ គ្រងការងារ ប្រចាំថ្ងៃដែល ប្រធានអាជ្ញាធរ ប្រគល់ឱ្យ សមាជិកអាជ្ញាធរ ត្រូវ គោរពតាមបទានុក្រមការងារដែលកំណត់ក្នុងឯកសារ **"តួនាទី រចនាសម្ព័ន្ធ និងភារកិច្ចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា"** ។

## **ជំពូកទី ៥**
## **អំពីលេខាធិការដ្ឋាន**

**មាត្រា ១៩. តួនាទីរបស់លេខាធិការដ្ឋាន**

អនុលោមតាមមាត្រា៨នៃច្បាប់ស្តីពីអគ្គិសនី អាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវមានលេខាធិការដ្ឋានមួយដើម្បីធ្វើកិច្ចការឱ្យអាជ្ញាធរអគ្គិសនីកម្ពុជា ។ លេខាធិការដ្ឋានមានតួនាទីជាសេនាធិការមួយរបស់អាជ្ញាធរដែលទទួលបន្ទុកធ្វើកិច្ចការរដ្ឋបាល និងកិច្ចការជំនាញផ្សេងៗពាក់ព័ន្ធនឹងភារកិច្ចរបស់អាជ្ញាធរដើម្បីដាក់ជូនសម័យ ប្រជុំ ឬ ប្រធានអាជ្ញាធរពិនិត្យសម្រេច ។

**មាត្រា ២០. រចនាសម្ព័ន្ធរបស់លេខាធិការដ្ឋាន**

**លេខាធិការដ្ឋាន** អាចមាន **នាយកដ្ឋាន ៤ នៅក្រោមចំណុះ** ។ នាយកដ្ឋាននិមួយៗទទួលបន្ទុកកិច្ចការជំនាញរបស់អាជ្ញាធរមួយផ្នែក និងអាចមានការិយាល័យមួយចំនួននៅក្រោមឱវាទ ។ នាយកដ្ឋានទាំង ៤ នេះមានដូចខាងក្រោម ÷

| | | |
|---|---|---|
| **១.** | **នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក** | ( Administrative and Personnel Department ) |
| **២.** | **នាយកដ្ឋានបញ្ញត្តិកម្មអគ្គិសនី** | ( Electricity Regulation Department ) |
| **៣.** | **នាយកដ្ឋានហិរញ្ញវត្ថុ និងតម្លៃ** | ( Financial and Pricing Department ) |
| **៤.** | **នាយកដ្ឋាននីតិកម្ម** | ( Legislation Department ) |

លេខាធិការដ្ឋាន ត្រូវដឹកនាំដោយ **នាយកប្រតិបត្តិ** ១រូប ។

តួនាទី រចនាសម្ព័ន្ធ និងភារកិច្ចលំអិតរបស់លេខាធិការដ្ឋានកំណត់ក្នុងឯកសារស្តីពី **"តួនាទី រចនាសម្ព័ន្ធ និងភារកិច្ចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា"** ។

**មាត្រា ២១. នាយកប្រតិបត្តិ**

នាយកប្រតិបត្តិគឺជាសេនាធិការរបស់អាជ្ញាធរ សម្រាប់ដឹកនាំការអនុវត្តការងារប្រចាំថ្ងៃរបស់លេខាធិការដ្ឋាន ។ នាយកប្រតិបត្តិត្រូវគ្រប់គ្រងកិច្ចការរបស់លេខាធិការដ្ឋានស្របតាមច្បាប់ បទបញ្ជាផ្ទៃក្នុងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ព្រមទាំងបទប្បញ្ញត្តិ បែបបទ នីតិវិធីនានា និងរចនាសម្ព័ន្ធគ្រប់គ្រងការងារ ដែលអនុម័តដោយសម័យប្រជុំ ។

នាយកប្រតិបត្តិត្រូវតែងតាំងឬដកចេញដោយប្រធានអាជ្ញាធរ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសមាជិកដទៃទៀត ស្របតាមការកំណត់របស់មាត្រា១៩ នៃច្បាប់ស្តីពីអគ្គិសនី និងស្របតាមការកំណត់ក្នុងជំពូក៦ នៃបទបញ្ជាផ្ទៃក្នុងនេះ ។

**នាយកប្រតិបត្តិ** មានភារកិច្ចដូចតទៅ :

១- គ្រប់គ្រងលេខាធិការដ្ឋាន និងអនុវត្តសេចក្តីសម្រេចទាំងឡាយរបស់អាជ្ញាធរ

២- ចាត់ចែង រៀបចំ និងដាក់ជូនអាជ្ញាធរពិនិត្យនូវយុទ្ធសាស្ត្រ និងផែនការរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

៣- តំណាងឱ្យលេខាធិការដ្ឋានអាជ្ញាធរអគ្គិសនីកម្ពុជា ចំពោះមុខក្រសួង ស្ថាប័នរដ្ឋ អាជ្ញាធរដែនដី សេវាករ និងតុលាការ ក្នុងការងារបំពេញភារកិច្ចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

៤- ចាត់ចែងឱ្យមន្ត្រីលេខាធិការដ្ឋាន រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ដោយមានគម្រោងចំណូលកម្រៃអាជ្ញាប័ណ្ណ និងគម្រោងចំណាយដាក់ជូនអាជ្ញាធរអគ្គិសនីកម្ពុជាពិនិត្យ និងអនុម័ត

៥- ធានាឱ្យការអនុវត្តបណ្តាភារកិច្ច និងការងារផ្សេងៗ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាបានប្រគល់ជូនប្រព្រឹត្តទៅបានត្រឹមត្រូវ និងទាន់ពេលវេលា

៦- រៀបចំចាត់ចែងការអនុវត្តការងារបញ្ញត្តិកម្មអគ្គិសនី ការងារហិរញ្ញវត្ថុនិងការកំណត់ថ្លៃ ការងារដោះស្រាយវិវាទនិងដាក់ពិន័យ និងការងាររដ្ឋបាលនិងបុគ្គលិក ឱ្យបានប្រសើរតាមគោលដៅរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

៧- បំពេញគ្រប់ភារកិច្ចនិងមុខងារផ្សេងទៀត ដែលច្បាប់និងអាជ្ញាធរអគ្គិសនីកម្ពុជាបានប្រគល់ឱ្យ ។

## ជំពូកទី ៦

## អំពីការជ្រើសរើស តែងតាំង ដកហូតតួនាទី មន្ត្រី-បុគ្គលិក

**មាត្រា ២២. ការផ្ទេរនិងជ្រើសរើសមន្ត្រី-បុគ្គលិកនៅពេលចាប់ផ្តើមបង្កើតអាជ្ញាធរអគ្គិសនីកម្ពុជាដំបូង**

នៅពេលបង្កើតអាជ្ញាធរដំបូង មន្ត្រី-បុគ្គលិករបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អគ្គិសនីកម្ពុជា ឬស្ថាប័នរដ្ឋដទៃទៀត អាចផ្ទេរជាស្វ័យប្រវត្តិមកក្នុងក្របខ័ណ្ឌរបស់អាជ្ញាធរអគ្គិសនីកម្ពុជា បើសិនជាសាមីខ្លួនស្ម័គ្រចិត្ត និងមានការយល់ព្រមពីប្រធានអាជ្ញាធរ ។ ការផ្ទេរនេះទាមទារ

ឱ្យមានពាក្យស្នើសុំចូលធ្វើការនៅអាផ្ទាធរអគ្គិសនីកម្ពុជាដោយស្ម័គ្រចិត្តលាលែងពីក្របខ័ណ្ឌដើម និងមានការយល់ព្រមពីប្រធានអាផ្ទាធរ ។

នៅពេលបង្កើតអាផ្ទាធរអគ្គិសនីកម្ពុជាដំបូងដែលពុំទាន់មានមន្ត្រីទទួលខុសត្រូវ ប្រធានអាផ្ទាធរអាចធ្វើការជ្រើសរើសមន្ត្រី–បុគ្គលិកដែលត្រូវការចាំបាច់បន្ថែម បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសមាជិកដទៃទៀត ។

## មាត្រា ២៣_ ការជ្រើសរើសមន្ត្រី_បុគ្គលិកជាប់លាប់

ផ្អែកតាមតម្រូវការចាំបាច់របស់អាផ្ទាធរអគ្គិសនីកម្ពុជា ប្រធានអាផ្ទាធរអាចសម្រេចជ្រើសរើស ឬជួលមន្ត្រី–បុគ្គលិកឱ្យចូលបម្រើការងារក្នុងអាផ្ទាធរអគ្គិសនីកម្ពុជា។ លើកលែងតែក្នុងពេលបង្កើតអាផ្ទាធរអគ្គិសនីកម្ពុជាដំបូង ការជ្រើសរើសមន្ត្រី–បុគ្គលិកជាប់លាប់ត្រូវឆ្លងកាត់ការជ្រើសរើសនិងការសាកល្បងការងារដូចអធិប្បាយខាងក្រោម ÷

### ក- <u>ការជ្រើសរើស</u>

ការជ្រើសរើសត្រូវធ្វើឡើងតាមរយៈគណៈកម្មការជ្រើសរើស និងត្រូវសម្រេចដោយប្រធានអាផ្ទាធរ ។ បេក្ខជនទាំង២ភេទនឹងត្រូវបានជ្រើសរើសឱ្យចូលសាកល្បងការងារ លុះត្រាតែសាមីជនបានបំពេញល័ក្ខខ័ណ្ឌ ដូចខាងក្រោម ÷

- បំពេញបាននូវលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើស
- បំពេញសំណុំលិខិតនិងបែបបទនៃការសុំចូលបម្រើការងារបានគ្រប់គ្រាន់និងត្រឹមត្រូវ
- បានទទួលការវាយតម្លៃជាវិជ្ជមានពីគណៈកម្មការជ្រើសរើស ដោយការប្រលងប្រជែង ឬការធ្វើតេស្តវាស់ស្ទង់សមត្ថភាព ឬការវាយតម្លៃដោយវិធីផ្សេងទៀត ។

លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសបេក្ខជនមាន: អាយុយ៉ាងតិច១៨ឆ្នាំ មានកិរិយាមាយាទល្អ មានកាយសម្បទាគ្រប់គ្រាន់ ព្រមទាំងមានសមត្ថភាពខាងវិជ្ជាជីវៈសមស្របតាមតម្រូវការរបស់អាផ្ទាធរអគ្គិសនីកម្ពុជា (កំណត់ក្នុងឯកសារ "តួនាទី រចនាសម្ព័ន្ធ និងភារកិច្ចរបស់អាផ្ទាធរអគ្គិសនីកម្ពុជា ")។

សំណុំលិខិតបែបបទសុំចូលបម្រើការងារ មានដូចខាងក្រោម ÷

- ពាក្យសុំចូលបម្រើការងារមានបិទតែម ៣ច្បាប់
- ប្រវត្តិរូបសង្ខេបមានបិទរូបថត៤គុណ៦ ៣ច្បាប់
- ច្បាប់ចម្លងសំបុត្រកំណើត ១ច្បាប់
- លិខិតបញ្ជាក់កិរិយាមាយាទ ១ច្បាប់
- លិខិតបញ្ជាក់សុខភាព ១ច្បាប់
- ច្បាប់ចម្លងសញ្ញាប័ត្រចំណេះដឹងទូទៅ ឬសញ្ញាប័ត្រជំនាញវិជ្ជាជីវៈ ១ច្បាប់
- លិខិតបញ្ជាក់ពីបទពិសោធន៍វិជ្ជាជីវៈ (ក្នុងករណីមាន) ១ច្បាប់

### ៩- រយៈពេលសាកល្បង

- អ្នកដែលត្រូវបានសម្រេចជ្រើសរើសឱ្យចូលធ្វើការងារ ត្រូវឆ្លងកាត់ការសាកល្បងការងារដែលមានថិរវេលា៣ខែចំពោះមន្ត្រី-បុគ្គលិក ២ខែចំពោះកម្មករជំនាញ និង១ខែចំពោះកម្មករធម្មតា ។
- អ្នកសាកល្បងការងារត្រូវស្ថិតនៅក្រោមអានុភាពនៃបទបញ្ជាផ្ទៃក្នុង បទបញ្ញត្តិនានារបស់អាជ្ញាធរអគ្គិសនីកម្ពុជា និងល័ក្ខខ័ណ្ឌការងារដូចមន្ត្រី-បុគ្គលិកក្នុងក្របខ័ណ្ឌដែរ។ ក្នុងរយៈពេលសាកល្បង អ្នកសាកល្បងការងារមិនត្រូវបានអនុញ្ញាតច្បាប់ឱ្យឈប់សម្រាកទេ លើកលែងតែថ្ងៃឈប់សម្រាកការងាររបស់មន្ត្រី-បុគ្គលិករបស់អាជ្ញាធរអគ្គិសនីកម្ពុជា និងក្នុងករណីពិសេសបំផុតប៉ុណ្ណោះ ។

### ច- ការចូលពេញសិទ្ធិក្នុងក្របខ័ណ្ឌ

ក្រោយចប់ការសាកល្បង អ្នកសាកល្បងការងារនឹងត្រូវទទួលការវាយតម្លៃនិងដាក់ពិន្ទុពីអ្នកគ្រប់គ្រងការងាររបស់ខ្លួនបន្តបន្ទាប់ តាមលក្ខណៈវិនិច្ឆ័យដែលកំណត់ក្នុងព្រឹត្តិប័ត្រពិន្ទុ ។

ការចូលពេញសិទ្ធិក្នុងក្របខ័ណ្ឌ ការពន្យាររយៈពេលសាកល្បង ការលុបឈ្មោះចេញពីបញ្ជីវិញត្រូវសម្រេចដោយប្រធានអាជ្ញាធរ ។

ព្រឹត្តិប័ត្រពិន្ទុត្រូវធ្វើតាមការកំណត់ក្នុងមាត្រា ២៤ ខាងក្រោម ។

## មាត្រា ២៤. ព្រឹត្តិប័ត្រពិន្ទុ

ព្រឹត្តិប័ត្រពិន្ទុគឺជាតារាងវាយតម្លៃការអនុវត្តការងាររបស់មន្ត្រី-បុគ្គលិក ដែលត្រូវប្រើប្រាស់សម្រាប់វាយតម្លៃសកម្មភាពការងារប្រចាំត្រីមាសរបស់មន្ត្រី-បុគ្គលិកក្នុងក្របខ័ណ្ឌ និងមន្ត្រី-បុគ្គលិកជួល ព្រមទាំងសម្រាប់វាយតម្លៃមន្ត្រី-បុគ្គលិកក្នុងរយៈពេលសាកល្បងផងដែរ ។

ព្រឹត្តិប័ត្រពិន្ទុនេះមានលក្ខណៈវិនិច្ឆ័យ៤សម្រាប់វាយតម្លៃ: ១-សមត្ថភាពជំនាញ ២-ទិន្នផលការងារ ៣-ការគោរពវិន័យ និង ៤-អត្តចរិត ។ ចំពោះសមត្ថភាពជំនាញ និងទិន្នផលការងារពិន្ទុដែលត្រូវវាយតម្លៃគឺពី ០ ដល់ ៦ អតិបរមា ។ ចំពោះការគោរពវិន័យ និងអត្តចរិតពិន្ទុដែលត្រូវវាយតម្លៃគឺពី ០ ដល់ ៤ អតិបរមា ។

### ក- ព្រឹត្តិប័ត្រពិន្ទុរបស់មន្ត្រី-បុគ្គលិកជាប់លាប់

ព្រឹត្តិប័ត្រពិន្ទុរបស់បុគ្គលិកធម្មតា ត្រូវវាយតម្លៃដោយប្រធានផ្នែកពាក់ព័ន្ធ ប្រធានការិយាល័យពាក់ព័ន្ធ និងប្រធាននាយកដ្ឋានពាក់ព័ន្ធ ដាច់ដោយឡែកពីគ្នា ។

ព្រឹត្តិប័ត្រពិន្ទុរបស់ប្រធាន-អនុប្រធានផ្នែក ត្រូវវាយតម្លៃដោយប្រធានការិយាល័យពាក់ព័ន្ធប្រធាននាយកដ្ឋានពាក់ព័ន្ធ និងនាយកប្រតិបត្តិ ដាច់ដោយឡែកពីគ្នា ។

ព្រឹត្តិប័ត្រពិន្ទុរបស់ប្រធាន-អនុប្រធានការិយាល័យ ត្រូវវាយតម្លៃដោយប្រធាននាយកដ្ឋានពាក់ព័ន្ធ នាយកប្រតិបត្តិ និងសមាជិកអាជ្ញាធរដែលទទួលបន្ទុក ដាច់ដោយឡែកពីគ្នា ។

ព្រឹត្តិប័ត្រពិន្ទុរបស់ប្រធាន-អនុប្រធាននាយកដ្ឋាន ត្រូវវាយតម្លៃដោយនាយកប្រតិបត្តិ និងសមាជិកអាជ្ញាធរទាំងបីរូប ដាច់ដោយឡែកពីគ្នា ។

ព្រឹត្តិប័ត្រពិន្ទុរបស់នាយកប្រតិបត្តិ ត្រូវវាយតម្លៃដោយសមាជិកអាជ្ញាធរទាំងបីរូប ដាច់ដោយឡែកពីគ្នា ។

នាយកដ្ឋានរដ្ឋបាលនិងបុគ្គលិកត្រូវបូកសរុបលទ្ធផល គណនាពិន្ទុមធ្យម និងរៀបចំតារាងរាយការណ៍ជូនថ្នាក់ដឹកនាំពិនិត្យ ។

## ខ- ព្រឹត្តិប័ត្រពិន្ទុរបស់បុគ្គលិកមិនជាប់លាប់( កិច្ចសន្យា)

ព្រឹត្តិប័ត្រពិន្ទុរបស់បុគ្គលិកមិនជាប់លាប់ ត្រូវវាយតម្លៃដោយប្រធានផ្នែកពាក់ព័ន្ធនឹងការងាររបស់បុគ្គលិកនោះ ប្រធានការិយាល័យពាក់ព័ន្ធ ប្រធាននាយកដ្ឋានពាក់ព័ន្ធ និងនាយកប្រតិបត្តិ ដាច់ដោយឡែកពីគ្នា ។ នាយកដ្ឋានរដ្ឋបាលនិងបុគ្គលិកត្រូវបូកសរុបលទ្ធផល គណនាពិន្ទុមធ្យមសម្រាប់ជាមូលដ្ឋានពិនិត្យអំពីលទ្ធភាពនៃការបន្តកិច្ចសន្យា ឬករណីផ្សេងទៀតដែលចាំបាច់ ។

## គ- ព្រឹត្តិប័ត្រពិន្ទុរបស់បុគ្គលិកសាកល្បង

ព្រឹត្តិប័ត្រពិន្ទុរបស់បុគ្គលិកសាកល្បង ត្រូវវាយតម្លៃដោយប្រធានផ្នែកពាក់ព័ន្ធនឹងការងាររបស់បុគ្គលិកនោះ ប្រធានការិយាល័យពាក់ព័ន្ធ ប្រធាននាយកដ្ឋានពាក់ព័ន្ធ និងនាយកប្រតិបត្តិ ដាច់ដោយឡែកពីគ្នា ។ នាយកដ្ឋានរដ្ឋបាលនិងបុគ្គលិកត្រូវបូកសរុបលទ្ធផល គណនាពិន្ទុមធ្យមសម្រាប់ជាមូលដ្ឋាននៃការពិនិត្យលទ្ធភាពឱ្យចូលពេញសិទ្ធិក្នុងក្របខ័ណ្ឌ ។

ព្រឹត្តិប័ត្រពិន្ទុសម្រាប់បុគ្គលិកក្នុងរយៈពេលសាកល្បង ត្រូវធ្វើឱ្យបានទាន់ពេលវេលាដើម្បីដាក់ភ្ជាប់ជាមួយសំណុំលិខិតបញ្ចប់ការសាកល្បង ។ ការកំណត់ឱ្យអ្នកសាកល្បងចូលពេញសិទ្ធិក្នុងក្របខ័ណ្ឌ ឬលុបឈ្មោះចេញពីបញ្ជីនៃអ្នកសាកល្បង ត្រូវផ្អែកលើល័ក្ខខ័ណ្ឌដូចខាងក្រោម ÷

- ពិន្ទុពី១៤ដល់២០ : អាចស្នើសុំពេញសិទ្ធិក្នុងក្របខ័ណ្ឌ
- ពិន្ទុពី១០ដល់១៣ : មិនអាចស្នើសុំពេញសិទ្ធិក្នុងក្របខ័ណ្ឌបានទេ តែអាចពន្យាររយៈពេលសាកល្បង២ខែទៅមុខទៀតដើម្បីធ្វើការវាយតម្លៃឡើងវិញ ។ ការពន្យាររយៈពេលសាកល្បងអាចធ្វើបានតែម្តងគត់ប៉ុណ្ណោះ។ ក្នុងករណីពិន្ទុលើកក្រោយនៅតែទាបជាង១៤ពិន្ទុ សាមីខ្លួននឹងត្រូវលុបឈ្មោះពីបញ្ជី ។
- ពិន្ទុពី៩ចុះក្រោម : ត្រូវលុបឈ្មោះចេញពីបញ្ជី ។

ក្រៅពីការពិនិត្យ និងសន្និដ្ឋានលើពិន្ទុសរុបដូចខាងលើនេះ បើសិនជាលក្ខណៈវិនិច្ឆ័យណាមួយក្នុងចំណោមលក្ខណៈវិនិច្ឆ័យទាំង៤ខាងលើបានពិន្ទុក្រោមមធ្យមនោះ សាមីខ្លួនក៏នឹងត្រូវលុបឈ្មោះចេញពីបញ្ជីដែរទោះជាបានពិន្ទុសរុបលើសពី១០ពិន្ទុក៏ដោយ ។

## មាត្រា ២៥- ការជ្រើសរើសជំនាញការ ជំនួយការ និងមន្ត្រី-បុគ្គលិកមិនជាប់លាប់

### ក- ជំនាញការ ឬជំនួយការ

ការជួលជំនាញការ ឬជំនួយការមកជួយការងារក្នុងអាជ្ញាធរ ត្រូវធ្វើតាមរយៈកិច្ចសន្យាការងារមួយចុះហត្ថលេខាដោយសាមីជនជាមួយនាយកប្រតិបត្តិ ឬតំណាងអាជ្ញាធរអគ្គិសនីកម្ពុជា ដែលមានការប្រគល់សិទ្ធិពីប្រធានអាជ្ញាធរ ។ ជំនាញការ ឬជំនួយការក្នុងស្រុក (មានន័យថាមានសញ្ជាតិជាខ្មែរ) អាចសុំចូលបម្រើការងារ និងទទួលចូលក្របខ័ណ្ឌពេញសិទ្ធិជាមន្ត្រីជាប់លាប់របស់អាជ្ញាធរបាននៅពេលផុតកំណត់កិច្ចសន្យាជាជំនាញការឬជំនួយការ ហើយសាមីខ្លួនបានបំពេញសំណុំលិខិតនិងបែបបទសុំចូលបម្រើការងារនៅអាជ្ញាធរ ព្រមទាំងបានទទួលការឯកភាពយល់ព្រមពីប្រធានអាជ្ញាធរ។ មុខងារនិងតួនាទីរបស់មន្ត្រីនេះ ត្រូវរៀបចំឡើងតាមការសម្រេចពីប្រធានអាជ្ញាធរ ដែលត្រូវធ្វើការពិគ្រោះយោបល់ជាមួយសមាជិកអាជ្ញាធរផ្សេងទៀត ។

### ខ- មន្ត្រី-បុគ្គលិកមិនជាប់លាប់

ចំពោះការងារដែលមិនមានលក្ខណៈជាប់លាប់ ឬការងារដែលត្រូវបំពេញក្នុងរយៈពេលខ្លី មន្ត្រី-បុគ្គលិកមួយចំនួន អាចត្រូវជ្រើសរើសឱ្យចូលបម្រើការងារនៅក្នុងអាជ្ញាធរអគ្គិសនីកម្ពុជាជាមន្ត្រី-បុគ្គលិកជួល ដែលត្រូវធ្វើឡើងតាមរយៈកិច្ចសន្យាការងារមួយ ចុះហត្ថលេខាដោយសាមីជនជាមួយនាយកប្រតិបត្តិ ឬតំណាងរបស់អាជ្ញាធរអគ្គិសនីកម្ពុជាដែលមានការប្រគល់សិទ្ធិពីប្រធានអាជ្ញាធរ ។

ក្នុងរយៈពេលនៃការបំពេញការងារតាមកិច្ចសន្យា មន្ត្រី-បុគ្គលិកជួលត្រូវស្ថិតនៅក្រោមអានុភាពនៃបទបញ្ជាផ្ទៃក្នុង បទប្បញ្ញត្តិនានារបស់អាជ្ញាធរអគ្គិសនីកម្ពុជា និងល័ក្ខខ័ណ្ឌការងារដូចមន្ត្រី-បុគ្គលិកជាប់លាប់ដែរ ព្រមទាំងត្រូវបានទទួលការវាយតម្លៃដាក់ពិន្ទុផងដែរ ។

មន្ត្រី-បុគ្គលិកជួលអាចជ្រើសរើសឱ្យចូលជាមន្ត្រី-បុគ្គលិកជាប់លាប់ជាស្វ័យប្រវត្តិ ប្រសិនបើ:

- សាមីខ្លួនត្រូវបានប្រើប្រាស់ក្នុងជំនាញណាមួយដែលមានរយៈពេលសរុបយ៉ាងតិច២ឆ្នាំ និងទទួលបានពិន្ទុស្មើនឹងពិន្ទុកំណត់សម្រាប់ការចូលពេញសិទ្ធិក្នុងក្របខ័ណ្ឌ ដូចមានចែងក្នុងមាត្រា ២៤ ខាងលើ
- មានតម្រូវការជ្រើសរើសចូលក្របខ័ណ្ឌ ដែលទាក់ទងទៅនឹងជំនាញដែលសាមីខ្លួនបានអនុវត្ត
- មានការស្នើសុំរបស់នាយកដ្ឋានជំនាញ នាយកប្រតិបត្តិ សមាជិកអាជ្ញាធរ និងមានការឯកភាពពីប្រធានអាជ្ញាធរ ។

**មាត្រា ២៦_ ការតែងតាំងមន្ត្រី_បុគ្គលិក**

ការតែងតាំងមន្ត្រី–បុគ្គលិកឱ្យទទួលតួនាទីណាមួយចាប់ពីអនុប្រធានផ្នែករហូតដល់នាយកប្រតិបត្តិ ត្រូវផ្អែកលើតម្រូវការជាក់ស្តែងនិងល័ក្ខខ័ណ្ឌនៃការតែងតាំង ។ ល័ក្ខខ័ណ្ឌនៃការតែងតាំងត្រូវបានកំណត់ដូចខាងក្រោម ÷

**ក-** **<u>តួនាទីនាយកប្រតិបត្តិ</u>**

- ត្រូវបានជ្រើសតាំងដោយមានការឯកភាពពីមតិភាគច្រើនរបស់សមាជិកអាជ្ញាធរ មានន័យថាត្រូវមានការឯកភាពពីសមាជិកអាជ្ញាធរយ៉ាងតិច២រូប ហើយចេញសេចក្តីសម្រេចប្រគល់តួនាទី និងភារកិច្ចដោយប្រធានអាជ្ញាធរ ។
- សំណើបេក្ខភាពតួនាទីនាយកប្រតិបត្តិត្រូវធ្វើឡើងដោយប្រធានអាជ្ញាធរ យោងតាមល័ក្ខខ័ណ្ឌសមត្ថភាពខាងវិជ្ជាជីវៈ ដែលមានកំណត់ក្នុង **"តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធគ្រប់គ្រងការងាររបស់អាជ្ញាធរអគ្គិសនីកម្ពុជា "** ។

**ខ-** **<u>តួនាទីប្រធាន -អនុប្រធាននាយកដ្ឋាន</u>**

- ត្រូវបានជ្រើសតាំងដោយប្រធានអាជ្ញាធរ ឆ្លងតាមការពិគ្រោះយោបល់ជាមួយសមាជិកអាជ្ញាធរ ហើយចេញសេចក្តីសម្រេចប្រគល់តួនាទី និងភារកិច្ចដោយប្រធានអាជ្ញាធរ ។
- នាយកប្រតិបត្តិអាចធ្វើសំណើបេក្ខភាពសម្រាប់តួនាទីនេះទៅប្រធានអាជ្ញាធរ ដោយយោងតាមល័ក្ខខ័ណ្ឌនៃសមត្ថភាពវិជ្ជាជីវៈដែលមានកំណត់ក្នុង **"តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធគ្រប់គ្រងការងាររបស់អាជ្ញាធរអគ្គិសនីកម្ពុជា "** ។

**គ-** **<u>តួនាទីប្រធាន -អនុប្រធានការិយាល័យ</u>**

- ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រី–បុគ្គលិក ដែលមានបទពិសោធន៍ក្នុងផ្នែកដែលត្រូវតែងតាំង ឬជ្រើសរើសពីក្រៅ ដោយយោងតាមល័ក្ខខ័ណ្ឌសមត្ថភាពវិជ្ជាជីវៈដែលមានកំណត់ក្នុង **"តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធគ្រប់គ្រងការងាររបស់អាជ្ញាធរអគ្គិសនីកម្ពុជា "** ដើម្បីសុំសេចក្តីសម្រេចពីប្រធានអាជ្ញាធរ ។
- ប្រធាននាយកដ្ឋានអាចធ្វើសំណើបេក្ខភាពសម្រាប់តួនាទីនេះទៅនាយកប្រតិបត្តិ ដើម្បីឱ្យនាយកប្រតិបត្តិពិនិត្យធ្វើសំណើទៅប្រធានអាជ្ញាធរ ។ ប្រធានអាជ្ញាធរអាចធ្វើការសម្រេចតែងតាំង បន្ទាប់ពីបានធ្វើការពិគ្រោះយោបល់ជាមួយសមាជិកដទៃទៀត ។

**ឃ-** **<u>តួនាទីប្រធាន -អនុប្រធានផ្នែក</u>**

- ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រី–បុគ្គលិកដែលមានបទពិសោធន៍ខ្ពស់ក្នុងផ្នែក ឬជ្រើសរើសពីក្រៅ ដោយយោងតាមល័ក្ខខ័ណ្ឌសមត្ថភាពវិជ្ជាជីវៈដែលមានកំណត់ក្នុង **"តួនាទី ភារកិច្ច**

**និងរចនាសម្ព័ន្ធគ្រប់គ្រងការងាររបស់អាជ្ញាធរអគ្គិសនីកម្ពុជា** " ដើម្បីសុំសេចក្តីសម្រេចពីប្រធានអាជ្ញាធរ ។

- ប្រធានការិយាល័យអាចធ្វើសំណើបេក្ខភាពសម្រាប់តួនាទីនេះទៅនាយកប្រតិបត្តិ ដោយឆ្លងការយល់ព្រមពីប្រធាននាយកដ្ឋាន ដើម្បីឱ្យនាយកប្រតិបត្តិពិនិត្យសម្រេចធ្វើសំណើទៅប្រធានអាជ្ញាធរ ។ ប្រធានអាជ្ញាធរអាចធ្វើការសម្រេចតែងតាំង បន្ទាប់ពីបានធ្វើការពិគ្រោះយោបល់ជាមួយសមាជិកដទៃទៀត ។

**មាត្រា ២៧៖ ការដកហូតតួនាទី**

មន្ត្រី-បុគ្គលិកក្នុងតួនាទីដឹកនាំណាមួយដែលខ្វះសមត្ថភាព ខ្វះស្មារតីទទួលខុសត្រូវ មានលទ្ធផលការងារទាបពុំអាចបំពេញការងារបានតាមតម្រូវការរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ឬបានប្រព្រឹត្តិកំហុសដែលពុំអាចអនុគ្រោះនិងកែលំអបាន អាជ្ញាធរអាចសម្រេចដកហូតតួនាទីដឹកនាំពីមន្ត្រីនោះវិញដោយរក្សាទុកឱ្យនៅជាមន្ត្រីធម្មតា ។ ក្នុងករណីនេះ សាមីខ្លួនត្រូវទទួលបៀវត្សតាមថ្នាក់-កាំរបស់ខ្លួនដដែល ប៉ុន្តែមិនត្រូវបានទទួលប្រាក់បំណាច់តួនាទីទៀតឡើយ ។ ការដកហូតតួនាទីដឹកនាំរបស់មន្ត្រី-បុគ្គលិកណាមួយត្រូវសម្រេចដោយការអនុម័តរបស់សម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ។

## ជំពូកទី ៧
## អំពីក្របខ័ណ្ឌរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

**មាត្រា ២៨៖ ថ្នាក់នៃក្របខ័ណ្ឌ**

ក្របខ័ណ្ឌរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវបានបែងចែកជាថ្នាក់ដោយកំណត់ទៅតាមកម្រិតជំនាញវិជ្ជាជីវៈពីទាបទៅខ្ពស់ដូចខាងក្រោមនេះ ÷

១- ថ្នាក់ទី១ : បុគ្គលិកគ្មានជំនាញ ( Unskill staff )

២- ថ្នាក់ទី២ : បុគ្គលិកដែលមានជំនាញអ្វីមួយច្បាស់លាស់ឬដែលមានសញ្ញាប័ត្រថ្នាក់កម្មករជំនាញ ( Skill staff )

៣- ថ្នាក់ទី៣ : បុគ្គលិកដែលមានសញ្ញាប័ត្រថ្នាក់បច្ចេកទេសជំនាញ ( Associate degree )

៤- ថ្នាក់ទី៤ : មន្ត្រីដែលមានសញ្ញាប័ត្រថ្នាក់បរិញ្ញាប័ត្រ ( Bachelor degree )

៥- ថ្នាក់ទី៥ : មន្ត្រីដែលមានសញ្ញាប័ត្រថ្នាក់ម៉ាស្ទ័រ ឬអនុបណ្ឌិត ( Master degree )

៦- ថ្នាក់ទី៦ : មន្ត្រីដែលមានសញ្ញាប័ត្រថ្នាក់បណ្ឌិត ឬជំនាញការ ឬមេធាវី ( Doctor degree or Expert or Lawyer )

ជំនាញការគឺជាបុគ្គលដែលមានបទពិសោធន៍ការងារខ្ពស់ និងមានសញ្ញាប័ត្រមាស្ទ័រឬអនុបណ្ឌិតឡើងទៅ ហើយត្រូវបានគេចាត់តាំងឱ្យធ្វើការងារជំនាញណាមួយច្បាស់លាស់យ៉ាងតិច៣ដងសម្រាប់រយៈពេលខ្លី (៦ខែ) ឬ១ដងសម្រាប់រយៈពេលវែង (យ៉ាងតិច២ឆ្នាំ) ។

មេធាវីគឺជាអ្នកច្បាប់ដែលមានសញ្ញាប័ត្រកម្រិត LLM និងត្រូវបានគេទទួលស្គាល់ចុះបញ្ជីជាមេធាវី ។

**មាត្រា ២៩. កាំ**

ថ្នាក់និមួយៗនៃក្របខ័ណ្ឌត្រូវបានបែងចែកជា ១២កាំ ។ កាំរបស់មន្ត្រី-បុគ្គលិកគឺជាសន្ទស្សន៍កំណត់មួយដែលឆ្លុះបញ្ចាំងនូវអតីតភាពនៃបទពិសោធន៍ការងារ រួមជាមួយនឹងលទ្ធផលនៃការអនុវត្តការងាររបស់មន្ត្រី-បុគ្គលិកនោះ ។ ការឆ្លងកាត់ពីកាំមួយទាបទៅកាំមួយខ្ពស់បន្ទាប់ត្រូវមានអតីតភាពដូចខាងក្រោម ÷

- ពីកាំ១ ដល់កាំ៦ : អតីតភាពយ៉ាងតិច០២ឆ្នាំក្នុងមួយកាំ
- ពីកាំ៦ ដល់កាំ១២ : អតីតភាពយ៉ាងតិច០៣ឆ្នាំក្នុងមួយកាំ ។

**មាត្រា ៣០. ការរៀបចំថ្នាក់-កាំឱ្យមន្ត្រី-បុគ្គលិក**

មន្ត្រី-បុគ្គលិកទាំងអស់ ដែលត្រូវបានជ្រើសរើសឱ្យចូលបម្រើការងារជាមន្ត្រី-បុគ្គលិកជាប់លាប់ត្រូវរៀបបញ្ចូលទៅក្នុងលំដាប់ថ្នាក់-កាំនៃក្របខ័ណ្ឌរបស់អាជ្ញាធរអគ្គិសនីកម្ពុជា យោងតាមកម្រិតជំនាញវិជ្ជាជីវៈ បទពិសោធន៍ និងលទ្ធផលការងាររបស់មន្ត្រី-បុគ្គលិកនោះ ។ វិជ្ជាជីវៈរបស់មន្ត្រី-បុគ្គលិកដែលត្រូវយកមកវាយតម្លៃដើម្បីកំណត់ថ្នាក់ក្នុងក្របខ័ណ្ឌ ត្រូវតែជាវិជ្ជាជីវៈណាដែលអាជ្ញាធរអគ្គិសនីកម្ពុជាត្រូវការក្នុងការអនុវត្តការងាររបស់ខ្លួនដែលមានកំណត់ក្នុង **"តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធគ្រប់គ្រងការងាររបស់អាជ្ញាធរអគ្គិសនីកម្ពុជា"** ។

ការកំណត់កាំឱ្យមន្ត្រី-បុគ្គលិក ដែលត្រូវបានជ្រើសរើសឱ្យចូលបម្រើការងារនៅក្នុងអាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវឈរលើការវាយតម្លៃបញ្ចូលគ្នារវាងចំនួនឆ្នាំអតីតភាពនៃបទពិសោធន៍ការងារនៃជំនាញដែលកំណត់ខាងលើជាមួយនឹងលទ្ធផលការងារជាក់ស្តែងកន្លងមក ដែលស្ថាប័នមុនបានវាយតម្លៃ (កាំចាស់) ។

## មាត្រា ៣១ ការដំឡើងថ្នាក់ កាំឱ្យមន្ត្រី បុគ្គលិក

ចំពោះមន្ត្រី-បុគ្គលិកណាដែលបានបំពេញការសិក្សាបន្ថែម ហើយបានទទួលសញ្ញាប័ត្រវិជ្ជាជីវៈណាមួយមានកម្រិតខ្ពស់ជាងមុន ព្រមទាំងសមស្របតាមតម្រូវការរបស់អាជ្ញាធរអគ្គិសនីកម្ពុជាដែរនោះ នឹងត្រូវបានទទួលថ្នាក់ក្នុងក្របខ័ណ្ឌអាជ្ញាធរអគ្គិសនីកម្ពុជា ស្របតាមសញ្ញាប័ត្រថ្មីដូចបានកំណត់ក្នុងមាត្រា ២៨ខាងលើ ហើយត្រូវឋិតក្នុងកាំណាមួយនៃថ្នាក់ថ្មីដែលមានកម្រិតបៀវត្សខ្ពស់បន្ទាប់ពីបៀវត្សចាស់ ។

ការដំឡើងកាំឱ្យមន្ត្រី-បុគ្គលិកពីកាំមួយទៅកាំខ្ពស់បន្ទាប់មួយទៀត ត្រូវផ្អែកលើល័ក្ខខ័ណ្ឌដូចខាងក្រោម ÷

- មានអតីតភាពការងារក្នុងកាំដែលកំពុងស្ថិតនៅយ៉ាងតិចស្មើនឹងរយៈពេលឆ្លងកាត់ពីកាំមួយទៅកាំមួយខ្ពស់បន្ទាប់ដែលបានកំណត់ក្នុងមាត្រា ២៩ខាងលើ
- មធ្យមភាគនៃព្រឹត្តិប័ត្រពិន្ទុប្រចាំត្រីមាសទាំងអស់ក្នុងរយៈពេលនៃកាំដែលកំពុងស្ថិតនៅយ៉ាងតិចស្មើនឹង ១៤
- មានចំណាត់ថ្នាក់ស្ថិតនៅក្នុងចំនួនកំណត់របស់អាជ្ញាធរសម្រាប់ដំឡើងកាំក្នុងឆ្នាំនិមួយៗ
- មិនដែលទទួលទណ្ឌកម្មចាប់ពីកម្រិត៣ ដូចបានកំណត់ក្នុងជំពូកទី១០នៃបទបញ្ជាផ្ទៃក្នុងនេះ ។

# ជំពូកទី ៨
# អំពីបៀវត្ស និងអត្ថប្រយោជន៍បន្ថែម

## មាត្រា ៣២ ការកំណត់ប្រាក់បៀវត្សចំពោះមន្ត្រី បុគ្គលិកជាប់លាប់

បៀវត្សដែលត្រូវផ្តល់ឱ្យមន្ត្រី-បុគ្គលិកជាប់លាប់ ត្រូវកំណត់តាមសន្ទស្សន៍បៀវត្សនៃថ្នាក់-កាំរបស់មន្ត្រី-បុគ្គលិកនោះ ។ សន្ទស្សន៍បៀវត្សទាបជាងគេជាសន្ទស្សន៍បៀវត្សនៃថ្នាក់ទី១កាំ១ដែលស្មើនឹង១,០០ ។ បៀវត្សអប្បបរមាគឺជាបៀវត្សនៃបុគ្គលិកដែលមានថ្នាក់ទី១កាំ១ ។

ប្រាក់បៀវត្សរបស់មន្ត្រី-បុគ្គលិកនិមួយៗ ត្រូវស្មើនឹងបៀវត្សអប្បបរមាគុណនឹងសន្ទស្សន៍នៃថ្នាក់-កាំរបស់មន្ត្រី-បុគ្គលិកនោះ ។ បៀវត្សអប្បបរមាសម្រាប់ឆ្នាំការិយបរិច្ឆេទនិមួយៗ ត្រូវកំណត់ដោយសម័យប្រជុំរបស់អាជ្ញាធរ ដើម្បីដាក់ក្នុងគម្រោងថវិកាប្រចាំឆ្នាំ ស្នើសុំការសម្រេចពីរាជរដ្ឋាភិបាល ។

ក្នុងរយៈពេលសាកល្បងការងារ អ្នកសាកល្បងការងារអាចទទួលបៀវត្សត្រឹមតែ៩០%ប៉ុណ្ណោះ។

សន្ទស្សន៍បៀវត្សសម្រាប់គណនាប្រាក់បៀវត្ស ត្រូវកំណត់ដូចក្នុងតារាងខាងក្រោម ÷

| | **ថ្នាក់ទី១**<br>បុគ្គលិកគ្មានជំនាញ | **ថ្នាក់ទី២**<br>បុគ្គលិកជំនាញ | **ថ្នាក់ទី៣**<br>អ្នកបច្ចេកទេស | **ថ្នាក់ទី៤**<br>អ្នកបរិញ្ញាប័ត្រ | **ថ្នាក់ទី៥**<br>ម៉ាស្ទ័រ<br>ឬអនុបណ្ឌិត | **ថ្នាក់ទី៦**<br>បណ្ឌិត, ជំនាញការ<br>ឬមេធាវី |
|---|---|---|---|---|---|---|
| កាំ១ | ១,០០០ | ១,៩៩៩ | ២,៩៣៧ | ៣,៩៩៦ | ៥,០៣៤ | ៦,៣៤១ |
| កាំ២ | ១,០៨០ | ២,១៥៩ | ៣,១៧២ | ៤,៣១៦ | ៥,៤៣៧ | ៦,៨៤៨ |
| កាំ៣ | ១,១៦៦ | ២,៣៣២ | ៣,៤២៦ | ៤,៦៦១ | ៥,៨៧១ | ៧,៣៩៦ |
| កាំ៤ | ១,២៦០ | ២,៥១៨ | ៣,៧០០ | ៥,០៣៤ | ៦,៣៤១ | ៧,៩៨៨ |
| កាំ៥ | ១,៣៦០ | ២,៧២០ | ៣,៩៩៦ | ៥,៤៣៧ | ៦,៨៤៨ | ៨,៦២៧ |
| កាំ៦ | ១,៤៦៩ | ២,៩៣៧ | ៤,៣១៦ | ៥,៨៧១ | ៧,៣៩៦ | ៩,៣១៧ |
| កាំ៧ | ១,៥៨៧ | ៣,១៧២ | ៤,៦៦១ | ៦,៣៤១ | ៧,៩៨៨ | ១០,០៦៣ |
| កាំ៨ | ១,៧១៤ | ៣,៤២៦ | ៥,០៣៤ | ៦,៨៤៨ | ៨,៦២៧ | ១០,៨៦៨ |
| កាំ៩ | ១,៨៥១ | ៣,៧០០ | ៥,៤៣៧ | ៧,៣៩៦ | ៩,៣១៧ | ១១,៧៣៧ |
| កាំ១០ | ១,៩៩៩ | ៣,៩៩៦ | ៥,៨៧១ | ៧,៩៨៨ | ១០,០៦៣ | ១២,៦៧៦ |
| កាំ១១ | ២,១៥៩ | ៤,៣១៦ | ៦,៣៤១ | ៨,៦២៧ | ១០,៨៦៨ | ១៣,៦៩០ |
| កាំ១២ | ២,៣៣២ | ៤,៦៦១ | ៦,៨៤៨ | ៩,៣១៧ | ១១,៧៣៧ | ១៤,៧៨៥ |

កំណើនសន្ទស្សន៍បៀវត្សពីកាំមួយទៅកាំមួយខ្ពស់បន្ទាប់ទៀតកំណត់ស្មើនឹង៨% ។

## មាត្រា ៣៣៖ ការផ្តល់ប្រាក់បៀវត្សឱ្យជំនាញការ ជំនួយការ ឬបុគ្គលិកជួល

ការផ្តល់បៀវត្សរដល់ជំនាញការ ជំនួយការ ឬបុគ្គលិកជួលត្រូវផ្អែកតាមកម្រៃដែលបានកំណត់ក្នុងកិច្ចសន្យាការងាររវាងជំនាញការ ជំនួយការ ឬបុគ្គលិកជួលនោះជាមួយអាជ្ញាធរអគ្គិសនីកម្ពុជា ។

## មាត្រា ៣៤៖ អត្ថប្រយោជន៍បន្ថែម

ក្រៅពីប្រាក់បៀវត្សជាមូលដ្ឋាន មន្ត្រី-បុគ្គលិកជាប់លាប់របស់អាជ្ញាធរអគ្គិសនីកម្ពុជាអាចទទួលបាននូវអត្ថប្រយោជន៍បន្ថែមផ្សេងទៀត ដូចខាងក្រោម ÷

- ប្រាក់បំណាច់ប៉ះពាល់សុខភាព
- ប្រាក់បំណាច់តួនាទី
- ប្រាក់កម្រៃបេសកកម្ម
- ប្រាក់ឧបត្ថម្ភពិធីបុណ្យទានធំៗ
- ប្រាក់កម្រៃម៉ោងបន្ថែម
- អត្ថប្រយោជន៍គ្រួសារ

ល័ក្ខខ័ណ្ឌនៃការផ្តល់អត្ថប្រយោជន៍បន្ថែម ត្រូវបានកំណត់ដូចខាងក្រោមនេះ ÷

### ក. ប្រាក់បំណាច់ប៉ះពាល់សុខភាព

ប្រាក់ប៉ះពាល់សុខភាព ត្រូវបានផ្តល់ចំពោះតែមន្ត្រី-បុគ្គលិក ដែលបំពេញភារកិច្ចលើការងារមានលក្ខណៈប៉ះពាល់សុខភាព ស្រាល មធ្យម ធ្ងន់ តែប៉ុណ្ណោះ ។

ការកំណត់ពីការងារមានលក្ខណៈប៉ះពាល់ដល់សុខភាព និងទឹកប្រាក់បំណាច់ប៉ះពាល់សុខភាព ត្រូវបានសម្រេចដោយប្រធានអាជ្ញាធរ តាមរយៈគណៈកម្មការមួយដែលបានចាត់តាំងឡើងដោយសម័យប្រជុំរបស់អាជ្ញាធរ ។

### ខ. ប្រាក់បំណាច់តួនាទី

ប្រាក់បំណាច់តួនាទីផ្តល់ឱ្យចំពោះតែមន្ត្រី ដែលមានតួនាទីដឹកនាំចាប់ពីអនុប្រធានផ្នែករហូតដល់ប្រធានអាជ្ញាធរ ។ កម្រិតប្រាក់បំណាច់តាមតួនាទីនិមួយៗ ត្រូវកំណត់ដោយសម័យប្រជុំរបស់អាជ្ញាធរ ។ ការផ្តល់ប្រាក់បំណាច់តួនាទីក្រៅពីសមាជិកអាជ្ញាធរ ត្រូវផ្អែកលើសេចក្តីសម្រេចតែងតាំងតួនាទីរបស់ប្រធានអាជ្ញាធរ ។

### គ. ប្រាក់កម្រៃបេសកកម្ម

#### ១-បេសកកម្មក្នុងប្រទេស

| ល.រ | ថ្នាក់ | ស្នាក់នៅ | ហូបចុក | ប្រាក់ហោប៉ៅ | សោហ៊ុយធ្វើដំណើរ |
|---|---|---|---|---|---|
| ១ | មន្ត្រី-បុគ្គលិកធម្មតា | 15$/យប់ | 15.000 ៛/ថ្ងៃ | 10.000 ៛/ថ្ងៃ | តាមជាក់ស្តែង |
| ២ | អនុប្រធាន-ប្រធានការិយាល័យ | 15$/យប់ | 17.000 ៛/ថ្ងៃ | 12.000 ៛/ថ្ងៃ | តាមជាក់ស្តែង |
| ៣ | អនុប្រធាន-ប្រធាននាយកដ្ឋាន | 20$/យប់ | 21.000 ៛/ថ្ងៃ | 15.000 ៛/ថ្ងៃ | តាមជាក់ស្តែង |
| ៤ | នាយកប្រតិបត្តិ | 25$/យប់ | 30.000 ៛/ថ្ងៃ | 20.000 ៛/ថ្ងៃ | តាមជាក់ស្តែង |
| ៥ | សមាជិកអាជ្ញាធរ | 40$/យប់ | 50.000 ៛/ថ្ងៃ | 30.000 ៛/ថ្ងៃ | តាមជាក់ស្តែង |

#### ២-បេសកកម្មក្រៅប្រទេស

ការចេញបេសកកម្មទៅក្រៅប្រទេស ដោយភាគីបរទេសជាអ្នករ៉ាប់រងសោហ៊ុយចំណាយទាំងស្រុង ត្រូវបានទទួលនូវការឧបត្ថម្ភជាប្រាក់ហោប៉ៅ និងពន្ធព្រលានយន្តហោះដូចខាងក្រោម ÷

| ល.រ | ថ្នាក់ | ប្រាក់ហោប៉ៅ | ពន្ធព្រលានយន្តហោះ | កម្រិតឧបត្ថម្ភខ្ពស់បំផុត |
|---|---|---|---|---|
| ១ | មន្ត្រី-បុគ្គលិកធម្មតា | 20$/ថ្ងៃ | តាមជាក់ស្តែង | ១០ថ្ងៃ |
| ២ | អនុប្រធាន-ប្រធានការិយាល័យ | 25$/ថ្ងៃ | តាមជាក់ស្តែង | ១០ថ្ងៃ |
| ៣ | អនុប្រធាន-ប្រធាននាយកដ្ឋាន | 30$/ថ្ងៃ | តាមជាក់ស្តែង | ១០ថ្ងៃ |
| ៤ | នាយកប្រតិបត្តិ | 35$/ថ្ងៃ | តាមជាក់ស្តែង | ១០ថ្ងៃ |
| ៥ | សមាជិកអាជ្ញាធរ | 50$/ថ្ងៃ | តាមជាក់ស្តែង | ១០ថ្ងៃ |

ដោយឡែក ចំពោះការចេញបេសកកម្មក្រៅប្រទេសដែលមិនមានការរ៉ាប់រងពីភាគីបរទេស កម្រៃបេសកកម្មត្រូវគិតតាមគម្រោងចំណាយជាក់ស្តែងបន្ថែមពីលើប្រាក់ហោប៉ៅ និងពន្ធព្រលានយន្តហោះខាងលើ ។ ចំពោះសមាជិកអាជ្ញាធរ បេសកកម្មក្នុងនិងក្រៅប្រទេសក្នុងកិច្ចការរបស់អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវបានកំណត់ ដោយប្រធានអាជ្ញាធរ ។

### ឃ. ប្រាក់ឧបត្ថម្ភពិធីបុណ្យទានធំៗ

សម្រាប់ក្នុងពិធីបុណ្យជាតិធំៗដូចជាបុណ្យចូលឆ្នាំប្រពៃណីជាតិ បុណ្យភ្ជុំបិណ្ឌជាដើម អាជ្ញាធរអគ្គិសនីកម្ពុជាអាចផ្តល់ឱ្យមន្ត្រី-បុគ្គលិកនូវប្រាក់ឧបត្ថម្ភពិធីបុណ្យ យោងតាមស្ថានភាពជាក់ស្តែងនៃគម្រោងថវិកា និងចំណូលពីកម្រៃអាជ្ញាប័ណ្ណ ។ ការសម្រេចលើការឧបត្ថម្ភ និងចំនួនដែលត្រូវឧបត្ថម្ភត្រូវអនុម័តដោយសម័យប្រជុំរបស់អាជ្ញាធរ ។

### ង. ប្រាក់កម្រៃបន្ថែមម៉ោង

ប្រាក់កម្រៃបន្ថែមម៉ោងត្រូវផ្តល់ឱ្យចំពោះតែមន្ត្រី-បុគ្គលិក ដែលត្រូវបានចាត់តាំងឱ្យធ្វើការងារស្នូលលើសម៉ោងកំណត់ ។ កម្រៃបន្ថែមម៉ោងដែលឧបត្ថម្ភឱ្យមន្ត្រី-បុគ្គលិកត្រូវកំណត់ដូចខាងក្រោម ÷

- លើសម៉ោង (ពេលថ្ងៃនៃថ្ងៃធម្មតា) = ១៥០% នៃបៀវត្សរ៍/ម៉ោង
- លើសម៉ោង (ពេលថ្ងៃនៃថ្ងៃសម្រាក) = ២០០% នៃបៀវត្សរ៍/ម៉ោង

ការផ្តល់ប្រាក់កម្រៃបន្ថែមម៉ោងត្រូវផ្អែកលើលិខិតចាត់តាំងធ្វើការលើសម៉ោងរបស់នាយកប្រតិបត្តិ ឬសមាជិកអាជ្ញាធរ ។

### ច. អត្ថប្រយោជន៍គ្រួសារ

- ឧបត្ថម្ភមន្ត្រី-បុគ្គលិកភេទស្រីពេលសម្រាលកូន : ស្មើបៀវត្សរ៍ ០១ខែ
- ឧបត្ថម្ភក្នុងករណីមរណភាពរបស់ប្តី ប្រពន្ធ និងកូនក្នុងបន្ទុក : ស្មើបៀវត្សរ៍ ០១ខែ
- ឧបត្ថម្ភដល់គ្រួសារក្នុងករណីមរណភាពរបស់សាមីខ្លួនជាមន្ត្រី-បុគ្គលិក :
  - ស្មើនឹងបៀវត្សរ៍ ០៩ខែ (អតីតភាពក្រោម០៥ឆ្នាំ)
  - ស្មើនឹងបៀវត្សរ៍ ១២ខែ (អតីតភាពចាប់ពី០៥ឆ្នាំឡើង)

### មាត្រា ៣៥. សៀវភៅបើកប្រាក់បៀវត្សរ៍

លេខាធិការដ្ឋានត្រូវរៀបចំឱ្យមានសៀវភៅបើកប្រាក់បៀវត្សរ៍មួយ ដែលមានគំរូនិងកំណត់ដោយប្រកាសរបស់ក្រសួងទទួលបន្ទុកវិស័យការងារ ។ សៀវភៅបើកប្រាក់នេះត្រូវមានចុះលេខគ្រប់ទំព័រ និងចុះហត្ថលេខារបស់ប្រធានអាជ្ញាធរ ។

សៀវភៅបើកប្រាក់បៀវត្សត្រូវរក្សាទុកក្នុងការិយាល័យបេឡា ដើម្បីងាយស្រួលក្នុងការត្រួតពិនិត្យ ។ កាលណាសៀវភៅនេះគ្រប់ទំព័រអស់ត្រូវថែរក្សាទុកក្នុងរយៈពេលបីឆ្នាំ ។ ប្រធានអាជ្ញាធរអាចទាររកសៀវភៅនេះនៅគ្រប់ពេលវេលា ។

សៀវភៅបើកប្រាក់បៀវត្សត្រូវមានកត់ត្រា :

- ពត៌មានស្តីពីមន្ត្រី-បុគ្គលិកម្នាក់ៗក្នុងអាជ្ញាធរអគ្គិសនីកម្ពុជា
- លក្ខណៈសំគាល់អំពីការងារ តួនាទី ប្រាក់កំម្រៃបៀវត្ស និងការឈប់សម្រាក ។

## ជំពូកទី ៩
## អំពីថិរវេលាធ្វើការងារ និងការឈប់សម្រាក

### មាត្រា ៣៦_ ថិរវេលា និងពេលម៉ោងធ្វើការងារ

ថិរវេលាធ្វើការងាររបស់មន្ត្រី-បុគ្គលិកអាជ្ញាធរអគ្គិសនីកម្ពុជាទាំងអស់ត្រូវកំណត់ ៨ម៉ោងក្នុង ១ថ្ងៃ និង ៥ថ្ងៃ ក្នុង ១សប្តាហ៍ ចាប់ពី ថ្ងៃច័ន្ទ រហូតដល់ ថ្ងៃសុក្រ ។

ក្នុងថ្ងៃធ្វើការ មន្ត្រី-បុគ្គលិកអាជ្ញាធរអគ្គិសនីកម្ពុជាទាំងអស់ពេលព្រឹកត្រូវចូលធ្វើការនៅម៉ោង៧ និង៣០នាទី និងចេញពីធ្វើការនៅម៉ោង១២គត់ ពេលល្ងាចត្រូវចូលធ្វើការនៅម៉ោង១៤គត់ និងចេញពីធ្វើការនៅម៉ោង១៧ និង៣០នាទី ។

ចំពោះមន្ត្រី-បុគ្គលិកដែលត្រូវបានចាត់តាំងឱ្យធ្វើការលើសម៉ោងនៅថ្ងៃធម្មតាឬថ្ងៃសម្រាក ហើយដែលមិនបានទទួលការទូទាត់ឱ្យឈប់សម្រាកសងវិញក្នុងរយៈពេលស្មើគ្នានោះ នឹងត្រូវបានទទួលជាប្រាក់កំម្រៃបន្ថែមម៉ោងដូចមានចែងក្នុងមាត្រា៣៤ខាងលើ លើកលែងតែក្រុមសន្តិសុខ ដែលត្រូវមានការផ្លាស់ប្តូរវេនយាម២៤ម៉ោង តាមតួនាទី ។

### មាត្រា ៣៧_ ការឈប់សម្រាកដោយមានបៀវត្ស

មន្ត្រី-បុគ្គលិកអាជ្ញាធរទាំងអស់ត្រូវបានឈប់សម្រាកដោយមានបៀវត្សដូចមានកំណត់ខាងក្រោម÷

**១- ឈប់សម្រាកប្រចាំសប្តាហ៍** : ការឈប់សម្រាកប្រចាំសប្តាហ៍ជាធម្មតាត្រូវកំណត់នៅថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ

**២- ឈប់សម្រាកថ្ងៃបុណ្យ** : ថ្ងៃបុណ្យដែលត្រូវចាត់ទុកជាថ្ងៃឈប់សម្រាកគឺថ្ងៃបុណ្យដែលកំណត់ដោយអនុក្រឹត្យស្តីពីប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករប្រចាំឆ្នាំ

**៣- ឈប់សម្រាកប្រចាំឆ្នាំ** : មន្ត្រី-បុគ្គលិកដែលបានបំពេញការងារអស់រយៈពេលមួយឆ្នាំជាប់រហូតដល់ដាច់ឆ្នាំ ត្រូវបានឈប់សម្រាកប្រចាំឆ្នាំទៅតាមកម្មវិធីកំណត់របស់អាជ្ញាធរ

អគ្គិសនីកម្ពុជានៅឆ្នាំបន្ទាប់ ដែលមានរយៈពេលដូចមានចែងក្នុងច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា

**៤- ឈប់សម្រាកលំហែមាតុភាព :** មន្ត្រី-បុគ្គលិកភេទស្រីដែលត្រូវសម្រាលកូន ត្រូវបានឈប់សម្រាកចំនួន៩០ថ្ងៃគិតទាំងការសម្រាកមុននិងក្រោយថ្ងៃសម្រាលកូន ។ ក្នុងករណីកូននៅមានអាយុក្រោម១ឆ្នាំ ស្ត្រីជាមាតាត្រូវបានអនុញ្ញាតឱ្យសម្រាកបន្ថែមមួយម៉ោង ក្នុង១ថ្ងៃដើម្បីបំបៅកូន ។

**៥- ឈប់សម្រាកដោយមានជំងឺ :** មន្ត្រី-បុគ្គលិកដែលមានជំងឺ ត្រូវបានអនុញ្ញាតឱ្យឈប់សម្រាក ដើម្បីព្យាបាលជំងឺក្នុងរយៈពេលមួយដែលកំណត់ដោយលិខិតបញ្ជាក់ពីមន្ទីរពេទ្យ ។ រយៈពេលឈប់សម្រាកព្យាបាលជំងឺអាចអនុញ្ញាតឱ្យបានយូរបំផុតស្មើនឹង ១២ខែ ។ មន្ត្រី-បុគ្គលិកដែលព្យាបាលជំងឺរយៈពេលវែងចំនួន១២ខែរួចហើយ ប៉ុន្តែនៅតែមិនអាចមានលទ្ធភាពត្រលប់មកបម្រើការងារវិញនោះនឹងត្រូវបានបញ្ឈប់ពីការងារ ។ ក្នុងករណីនេះ សាមីជនត្រូវបានទទួលប្រាក់ឧបត្ថម្ភម្តងគត់ស្មើនឹងបៀវត្សប្រចាំខែ និងប្រាក់បន្ទាប់បន្សំផ្សេងទៀតគុណនឹងចំនួនឆ្នាំអតីតភាព ប៉ុន្តែច្រើនបំផុតស្មើនឹង ៦ដង ។

**៦- ឈប់សម្រាកដោយធុរៈពិសេសផ្ទាល់ខ្លួន :** ការឈប់សម្រាកដោយធុរៈពិសេសផ្ទាល់ខ្លួននឹងត្រូវបានអនុញ្ញាតឱ្យតែក្នុងករណីដូចខាងក្រោម ÷

- អាពាហ៍ពិពាហ៍សាមីខ្លួន ៦ ថ្ងៃធ្វើការ
- ប្រពន្ធឆ្លងទន្លេ ៣ ថ្ងៃធ្វើការ
- អាពាហ៍ពិពាហ៍កូនបង្កើត ៣ ថ្ងៃធ្វើការ
- មរណភាពសាមីភរិយា-ប្តី ឪពុកម្តាយឬកូនបង្កើត ៥ ថ្ងៃធ្វើការ

រយៈពេលខាងលើនេះ នឹងត្រូវបានបន្ថែមពីលើនូវរយៈពេលធ្វើដំណើរផងដែរ ។

## មាត្រា ៣៨. ការកំណត់សម្រាប់ការឈប់សម្រាកដោយមានបៀវត្ស

ការឈប់សម្រាកប្រចាំសប្តាហ៍ ឈប់សម្រាកថ្ងៃបុណ្យ ឈប់សម្រាកលំហែមាតុភាព ឈប់សម្រាកព្យាបាលជំងឺ និងឈប់សម្រាកព្យាបាលដោយគ្រោះថ្នាក់ការងារ មិនត្រូវបានកាត់កងពីរយៈពេលឈប់សម្រាកប្រចាំឆ្នាំឡើយ ។

## មាត្រា ៣៩. ការឈប់សម្រាកផ្សេងទៀត

ក្រៅពីការឈប់សម្រាកដោយមានបៀវត្សខាងលើ មន្ត្រី-បុគ្គលិកអាជ្ញាធរអគ្គិសនីកម្ពុជាអាចត្រូវបានអនុញ្ញាតឱ្យឈប់សម្រាកដោយធុរៈផ្សេងទៀតបាន ប៉ុន្តែការឈប់សម្រាកនេះនឹងត្រូវបានកាត់កង

ពីរយៈពេលអនុញ្ញាតឱ្យឈប់សម្រាកប្រចាំឆ្នាំ ទៅតាមចំនួនថ្ងៃដែលបានឈប់ ។ ចំនួនថ្ងៃឈប់សម្រាកដែលលើសពីថ្ងៃអនុញ្ញាតឱ្យឈប់សម្រាកប្រចាំឆ្នាំនឹងមិនត្រូវបានទទួលបៀវត្សរ៍ឡើយ ។

សមត្ថកិច្ចក្នុងការអនុញ្ញាតច្បាប់ឈប់សម្រាក ត្រូវបានកំណត់ដូចខាងក្រោម ៖

- ចាប់ពី ០២ ថ្ងៃចុះ ត្រូវសម្រេចត្រឹមប្រធាននាយកដ្ឋានសាមីខ្លួន
- ចាប់ពី ០៣ ដល់ ០៧ថ្ងៃ ត្រូវសម្រេចដោយនាយកប្រតិបត្តិ
- ចាប់ពី ០៧ ថ្ងៃឡើង ត្រូវសម្រេចដោយប្រធានអាជ្ញាធរ ។

# ជំពូកទី ១០
# អំពីវិន័យ និងទណ្ឌកម្ម

## មាត្រា ៤០_ ការល្មើសវិន័យ

រាល់ករណីដែលចាត់ទុកជាអំពើល្មើសវិន័យរបស់មន្ត្រី-បុគ្គលិកគឺ ៖

១- សកម្មភាពមិនស្របច្បាប់ប៉ះពាល់ដល់សណ្តាប់ធ្នាប់របៀបរៀបរយ សុវត្ថិភាព សន្តិសុខផ្ទៃក្នុងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

២- អវត្តមានឥតច្បាប់អនុញ្ញាត មកធ្វើការយឺត ចេញមុនម៉ោងកំណត់

៣- អនុវត្តផ្ទុយពីបទបញ្ជាផ្ទៃក្នុង បទប្បញ្ញត្តិ និងសេចក្តីសម្រេចរបស់អាជ្ញាធរ ឬសេចក្តីណែនាំរបស់ថ្នាក់លើ

៤- ធ្វើឱ្យខូចខាតបាត់បង់ដោយចេតនានូវឧបករណ៍សម្ភារៈ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាបានប្រគល់ឱ្យប្រើប្រាស់បម្រើការងារ

៥- លួចកិបកេងទ្រព្យសម្បត្តិរបស់អាជ្ញាធរ ឬក្លែងបន្លំឯកសារ

៦- ឈ្លោះប្រកែក ជេរប្រមាថ ឬវាយដំចំពោះមន្ត្រី-បុគ្គលិកដទៃឬថ្នាក់លើ

៧- ឃោសនា ញុះញង់អ្នកដទៃ ឱ្យប្រព្រឹត្តអំពើខុសឆ្គង ឬបំបែកបំបាក់ផ្ទៃក្នុង

៨- ផ្សព្វផ្សាយពត៌មានមិនពិត ឬធ្វើសកម្មភាពប៉ះពាល់ដល់កិត្យានុភាពរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

៩- ធ្វើសកម្មភាពផ្ទុយពីខ្លឹមសារនៃច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា

១០- ធ្វើសកម្មភាពផ្ទុយពីច្បាប់រដ្ឋ ។

## មាត្រា ៤១_ ការកំណត់កម្រិតនៃការល្មើសវិន័យ

ការល្មើសវិន័យត្រូវបែងចែកជាកម្រិតធ្ងន់ស្រាលដូចខាងក្រោម ៖

**១-ល្មើសវិន័យកម្រិតទី១ :**

- ការប្រព្រឹត្តខុសឆ្គងស្រាលៗជាទូទៅ
- ការប្រព្រឹត្តល្មើសដូចចំណុច១ នៃមាត្រា ៤០
- ការមកធ្វើការយឺត និងចេញមុនម៉ោងកំណត់ដោយគ្មានការអនុញ្ញាត
- អវត្តមានឥតច្បាប់លើកទី១ ដែលមានរយៈពេលក្រោម ០៥ថ្ងៃ

**២-ល្មើសវិន័យកម្រិតទី២ :**

- ការមិនកែប្រែកំហុសបន្ទាប់ពីទទួលទណ្ឌកម្មកម្រិតទី១ ចំនួនពីរលើករួចមកហើយ (មិនរាប់បញ្ចូលករណីអវត្តមានផងទេ)
- អវត្តមានឥតច្បាប់លើកទី១ ចាប់ពី ០៥ថ្ងៃឡើងទៅ
- អវត្តមានឥតច្បាប់ ក្រោម០៥ថ្ងៃចុះ ជាលើកទី២
- ការប្រព្រឹត្តល្មើសដូចចំណុច ២-៣-៤-៥-៦-៧-៨ នៃមាត្រា ៤០

**៣-ល្មើសវិន័យកម្រិតទី៣ :**

- ការមិនកែប្រែកំហុសបន្ទាប់ពីទទួលទណ្ឌកម្មកម្រិតទី២ រួចហើយ
- ការប្រព្រឹត្តល្មើសដូចចំណុច ៤-៥-៩ នៃមាត្រា ៤០
- ការប្រព្រឹត្តល្មើសដូចចំណុច ៦-៧-៨ នៃមាត្រា ៤០ ដែលមានលក្ខណៈធ្ងន់ធ្ងរ

**៤-ល្មើសវិន័យកម្រិតទី៤ :**

- ការមិនកែប្រែកំហុសបន្ទាប់ពីទទួលទណ្ឌកម្មកម្រិតទី៣ រួចហើយ
- ការប្រព្រឹត្តល្មើសដូចចំណុច ៤-៥-៩ នៃមាត្រា ៤០ ដែលមានលក្ខណៈធ្ងន់ធ្ងរ
- ការមិនព្រមចូលខ្លួន តាមលិខិតកោះហៅលើកទី៣ ឬចូលខ្លួនក្រោយកាលកំណត់
- ធ្វើសកម្មភាពផ្ទុយពីខ្លឹមសារមាត្រា ១២ នៃច្បាប់ស្តីពីអគ្គិសនី
- ធ្វើសកម្មភាពផ្ទុយពីច្បាប់រដ្ឋ ។

### មាត្រា ៤២. ការដាក់ទណ្ឌកម្មចំពោះការល្មើសវិន័យ

ការល្មើសវិន័យត្រូវទទួលការដាក់ទណ្ឌកម្ម ។ កម្រិតនៃទណ្ឌកម្មត្រូវផ្អែកលើកម្រិតនៃការល្មើសវិន័យ ការល្មើសវិន័យកម្រិតទី១ត្រូវទទួលទណ្ឌកម្មកម្រិត១ ការល្មើសវិន័យកម្រិតទី២ត្រូវទទួលទណ្ឌកម្មកម្រិត២ ការល្មើសវិន័យកម្រិតទី៣ត្រូវទទួលទណ្ឌកម្មកម្រិត៣ និងការល្មើសវិន័យកម្រិតទី៤ត្រូវទទួលទណ្ឌកម្មកម្រិត៤ ។

ការដាក់ទណ្ឌកម្មតាមកម្រិតមានដូចខាងក្រោម ÷

- ទណ្ឌកម្មកម្រិតទី១ : ស្តីបន្ទោសណែនាំដោយផ្ទាល់មាត់

- ទណ្ឌកម្មកម្រិតទី២ : ព្រមានជាលាយល័ក្ខណ៍អក្សរលើកទី១ និងលើកទី២
- ទណ្ឌកម្មកម្រិតទី៣ : ព្រមានជាលាយល័ក្ខណ៍អក្សរលើកទី៣ និងព្យួរការងារ ចំនួន១០ថ្ងៃ ដោយគ្មានបៀវត្ស
- ទណ្ឌកម្មកម្រិតទី៤ : បញ្ឈប់ពីការងារ

ការមកធ្វើការយឺត និងចេញមុនម៉ោងដោយគ្មានការអនុញ្ញាតចំនួន ០៦ដង ត្រូវចាត់ទុកជាការអវត្តមានឥតច្បាប់ចំនួន ០១ថ្ងៃ ។

រាល់អវត្តមានឥតច្បាប់ត្រូវបានកាត់បន្ថយប្រាក់បៀវត្សទៅតាមចំនួនថ្ងៃដែលបានឈប់ ។ ក្រៅពីត្រូវទទួលការកាត់បន្ថយប្រាក់បៀវត្ស មន្ត្រី-បុគ្គលិកដែលឈប់ឥតច្បាប់លើកទី១ ក្នុងរយៈពេលសរុបក្រោម០៥ថ្ងៃនឹងត្រូវទទួលទណ្ឌកម្មកម្រិតទី១ តែបើមានលើកទី២ទៀតឬបើឈប់លើកទី១ ប៉ុន្តែមានរយៈពេលចាប់ពី ០៥ថ្ងៃឡើងនឹងត្រូវទទួលទណ្ឌកម្មកម្រិតទី២ ។

មន្ត្រី-បុគ្គលិកដែលបានធ្វើឱ្យខូចខាតបាត់បង់នូវឧបករណ៍សម្ភារៈ ឬលួចកិបកេងទ្រព្យសម្បត្តិរបស់អាជ្ញាធរអគ្គិសនីកម្ពុជាដោយការធ្វេសប្រហែសឬដោយចេតនា នឹងត្រូវតម្រូវឱ្យជួសជុលសងការខូចខាតក្នុងកម្រិតណាមួយឬទាំងស្រុងទៅតាមការវិនិច្ឆ័យរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ឬបើក្នុងករណីធ្ងន់ធ្ងរត្រូវបញ្ជូនទៅតុលាការ ដើម្បីវិនិច្ឆ័យតាមផ្លូវច្បាប់ ។

**មាត្រា ៤៣- សមត្ថកិច្ចក្នុងការដាក់ទណ្ឌកម្ម**

សមត្ថកិច្ចក្នុងការដាក់ទណ្ឌកម្មចំពោះមន្ត្រី-បុគ្គលិកដែលបានប្រព្រឹត្តខុសឆ្គង និងការតម្រូវឱ្យជួសជុលសងការខូចខាត ត្រូវបានបែងចែកដូចខាងក្រោមនេះ ÷

- ការដាក់ទណ្ឌកម្មកម្រិតទី១ ត្រូវធ្វើត្រឹមប្រធាននាយកដ្ឋាន
- ការដាក់ទណ្ឌកម្មកម្រិតទី២ ត្រូវធ្វើដោយនាយកប្រតិបត្តិ
- ការដាក់ទណ្ឌកម្មចាប់ពីកម្រិតទី៣ឡើងទៅ និងការតម្រូវឱ្យជួសជុលសងការខូចខាតត្រូវសម្រេចដោយប្រធានអាជ្ញាធរ ។

## ជំពូកទី ១១
## អំពីការបញ្ឈប់ និងការលាលែងពីការងារ

**មាត្រា ៤៤- ការបញ្ឈប់ពីការងារ**

មន្ត្រី-បុគ្គលិកអាជ្ញាធរអគ្គិសនីកម្ពុជាអាចនឹងត្រូវបញ្ឈប់ពីការងារដោយមូលហេតុដូចខាងក្រោម ÷

- ល្មើសនឹងវិន័យ
- អសមត្ថភាពខាងកាយសម្បទា ឬខ្វះលក្ខណៈជាមនុស្សក្នុងសង្គម

- ទទួលការផ្តន្ទាទោសពីតុលាការ
- ត្រូវបានរំសាយពីការងារ ក្នុងផែនការកាត់បន្ថយបុគ្គលិក

ការបញ្ឈប់មន្ត្រី-បុគ្គលិកពីការងារ ត្រូវអនុវត្តដូចខាងក្រោមនេះ ÷

- បញ្ឈប់ដោយមូលហេតុល្មើសនឹងវិន័យ ត្រូវផ្អែកលើទណ្ឌកម្មកម្រិតទី៤
- បញ្ឈប់ដោយមូលហេតុអសមត្ថភាពខាងកាយសម្បទា ឬខ្វះលក្ខណៈជាមនុស្សក្នុងសង្គម ត្រូវផ្អែកលើព្រឹត្តិប័ត្រវេជ្ជសាស្ត្ររបស់ក្រសួងសុខាភិបាលជាមូលដ្ឋាន
- បញ្ឈប់ដោយមូលហេតុផ្តន្ទាទោសពីតុលាការ ត្រូវផ្អែកលើសាលក្រមស្ថាពររបស់តុលាការ ។ ក្នុងកំឡុងពេលចាប់ពីមានការចោទប្រកាន់រហូតដល់ថ្ងៃចេញសាលក្រមស្ថាពរ ការងារ និងប្រាក់បៀវត្សរបស់សាមីខ្លួន នឹងព្យួរជាបណ្តោះអាសន្ន ។ ក្នុងករណីដែលតុលាការសម្រេចថាគ្មានទោស សាមីជននឹងត្រូវបានអនុញ្ញាតឱ្យចូលបម្រើការងារវិញ ហើយប្រាក់បៀវត្សដែលបានព្យួរត្រូវរំលឹកឱ្យសាមីជនវិញ ។
- បញ្ឈប់ដោយមូលហេតុត្រូវរំសាយពីការងារក្នុងផែនការកាត់បន្ថយបុគ្គលិក ត្រូវផ្អែកលើការសម្រេចរបស់សម័យប្រជុំ ។

## មាត្រា ៤៥. ការជូនដំណឹងមុនស្តីពីការបញ្ឈប់ពីការងារ

មន្ត្រី-បុគ្គលិកក្នុងក្របខ័ណ្ឌអាជ្ញាធរអគ្គិសនីកម្ពុជា ដែលបញ្ឈប់ពីការងារដោយមូលហេតុផ្សេងៗក្រៅពីល្មើសវិន័យនិងការផ្តន្ទាទោសពីតុលាការ ត្រូវបានទទួលការជូនដំណឹងមុនដែលមានរយៈពេលកំណត់ដូចចែងក្នុងច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា ។

ក្នុងកំឡុងពេលនៃការជូនដំណឹងមុនអំពីការបញ្ឈប់ពីការងារ សាមីជនមានសិទ្ធិឈប់សម្រាក២ថ្ងៃធ្វើការក្នុង១សប្តាហ៍ដោយមានប្រាក់បៀវត្ស ដើម្បីស្វែងរកការងារថ្មី ឬរៀបចំស្ថានភាពថ្មីរបស់ខ្លួន ។

## មាត្រា ៤៦. ការផ្តល់ប្រាក់ឧបត្ថម្ភដល់អ្នកត្រូវបញ្ឈប់ពីការងារ

មន្ត្រី-បុគ្គលិកក្នុងក្របខ័ណ្ឌដែលត្រូវបានបញ្ឈប់ពីការងារដោយមូលហេតុផ្សេងៗ ក្រៅពីល្មើសវិន័យ និងការផ្តន្ទាទោសពីតុលាការ ត្រូវបានទទួលប្រាក់ឧបត្ថម្ភពីអាជ្ញាធរអគ្គិសនីកម្ពុជាម្តងគត់ដូចបានកំណត់ក្នុងច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា ។

## មាត្រា ៤៧. ការផ្អាកការងារជាបណ្តោះអាសន្ន

ក្នុងករណីដែលអាជ្ញាធរអគ្គិសនីកម្ពុជាមានការចាំបាច់ ត្រូវផ្អាកការងារនៅផ្នែកខ្លះក្នុងរយៈពេលកំណត់ណាមួយ អាជ្ញាធរអាចមានសិទ្ធិព្យួរការងាររបស់មន្ត្រី-បុគ្គលិកផ្នែកនោះជាបណ្តោះអាសន្ន ដោយដាក់ឱ្យស្ថិតក្នុងភាពទំនេរគ្មានប្រាក់បៀវត្ស ។

**មាត្រា ៤៨. ការលាលែងពីការងារ**

មន្ត្រី-បុគ្គលិកក្នុងក្របខ័ណ្ឌដែលមានបំណងសុំលាលែងពីការងារ ត្រូវឱ្យដំណឹងជាលាយល័ក្ខណ៍អក្សរជាមុនមកអាជ្ញាធរអគ្គិសនីកម្ពុជាក្នុងរយៈពេលដូចមានកំណត់ក្នុងច្បាប់ស្តីពីការងារ ។

ក្នុងករណីបានការសម្រេចពីអាជ្ញាធរឱ្យឈប់ពីការងារតាមសំណូមពរហើយនោះ សាមីជននឹងត្រូវបានទទួលការឧបត្ថម្ភម្តងគត់ស្មើនឹងបៀវត្ស ១ខែ ។ ផ្ទុយទៅវិញការលាលែងពីការងារដោយពុំមានការសម្រេចយល់ព្រមពីអាជ្ញាធរទេនោះ ពុំត្រូវបានទទួលប្រាក់ឧបត្ថម្ភអ្វីឡើយ ។

## ជំពូកទី ១២
## អំពីគ្រោះថ្នាក់ការងារ

**មាត្រា ៤៩. ការព្យាបាល**

ក្នុងពេលបំពេញការងារមន្ត្រី-បុគ្គលិកដែលមានជំងឺ ឬគ្រោះថ្នាក់ការងារនឹងត្រូវបានពិនិត្យព្យាបាលជាបន្ទាន់ ។ ចំពោះមន្ត្រី-បុគ្គលិកដែលមានជំងឺត្រូវព្យាបាល ឬសម្រាកព្យាបាលនៅមន្ទីរពេទ្យយូរត្រូវបានទទួលការឧបត្ថម្ភពីអាជ្ញាធរអគ្គិសនីកម្ពុជា ស្មើនឹងបៀវត្សរបស់សាមីខ្លួនមួយខែក្នុងមួយឆ្នាំ ។

**មាត្រា ៥០. គ្រោះថ្នាក់ការងារ**

ត្រូវចាត់ទុកថាជាគ្រោះថ្នាក់ការងារ ចំពោះគ្រោះថ្នាក់ទាំងឡាយណាដែលធ្លាក់លើសាមីជនជាមន្ត្រី-បុគ្គលិកក្នុងក្របខ័ណ្ឌ ជំនាញការ អ្នកជំនួយការ និងបុគ្គលិកជួល :

- ក្នុងពេលកំពុងបំពេញការងារ
- ក្នុងពេលធ្វើដំណើរទៅមក ដើម្បីបំពេញការងារដែលបានប្រគល់អោយ
- ក្នុងលក្ខណៈមានជំងឺវិជ្ជាជីវៈ ដែលមានកំណត់ដោយច្បាប់ស្តីពីការងារ ។

**មាត្រា ៥១. ការដោះស្រាយចំពោះគ្រោះថ្នាក់ការងារ**

អាជ្ញាធរអគ្គិសនីកម្ពុជាទទួលរ៉ាប់រងសោហ៊ុយចំណាយជួសជុលគ្រោះថ្នាក់ការងារ ចំពោះមន្ត្រី-បុគ្គលិករងគ្រោះដោយគិតទាំងសោហ៊ុយព្យាបាល និងការចំណាយផ្សេងទៀត ដែលកំណត់ដោយច្បាប់ស្តីពីការងារ ។

ក្នុងករណីគ្រោះថ្នាក់ការងារណាមួយកើតឡើងដោយសារកំហុសសាមីខ្លួន សោហ៊ុយចំណាយជួសជុលគ្រោះថ្នាក់ការងារដែលអាជ្ញាធរអគ្គិសនីកម្ពុជាទទួលរ៉ាប់រងនោះ នឹងត្រូវកាត់បន្ថយឱ្យនៅត្រឹមតែ ៧០% នៃចំណាយសរុបតែប៉ុណ្ណោះ ។

**មាត្រា ៥២. ការដោះស្រាយចំពោះគ្រោះថ្នាក់ការងារធ្ងន់ធ្ងរ**

ចំពោះករណីគ្រោះថ្នាក់ការងារ ដែលបណ្តាលឱ្យបាត់បង់សមត្ថភាពពលកម្មជាអចិន្ត្រៃយ៍ ឬដល់ស្លាប់ អ្នកសិទ្ធវន្តនៃសាមីមន្ត្រី-បុគ្គលិកនឹងត្រូវបានទទួលប្រាក់ឧបត្ថម្ភម្តងគត់ស្មើនឹងបៀវត្សរ៍សរុប ១២ខែ ចំពោះអ្នកបម្រើការងារតិចជាង ០៥ឆ្នាំ និង ១៨ខែ ចំពោះអ្នកបម្រើការងារលើសពី ០៥ឆ្នាំ បន្ថែមលើសោហ៊ុយជួសជុលគ្រោះថ្នាក់ការងារដែលបានចំណាយរួចមកហើយ ។

## ជំពូកទី ១៣
## អំពីការចូលនិវត្តន៍

**មាត្រា ៥៣. ការដោះស្រាយចំពោះការចូលនិវត្តន៍**

មន្ត្រី-បុគ្គលិករបស់អាជ្ញាធរអគ្គិសនីកម្ពុជាទាំងអស់ត្រូវដាក់ឱ្យចូលនិវត្តន៍ ពេលដល់អាយុ៦០ឆ្នាំ។ ក្នុងករណីដែលមិនទាន់មានច្បាប់ស្តីពីការធានាជរាភាព ទុព្វលភាព និងមរណភាព ការចូលនិវត្តន៍ និងការចូលបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវផ្អែកតាមគោលការណ៍នៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៩៤ អនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩៧ និងលិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ២១៩ សជណ.អវ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ១៩៩៨ ។

ការគិតប្រាក់សោធននិវត្តន៍ ឬប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈ និងប្រាក់ឧបត្ថម្ភផ្តាច់តែម្តងគត់ ត្រូវយកប្រភេទកាំបៀវត្សរ៍របស់សាមីខ្លួនធ្វើជាមូលដ្ឋានគិត ។

**មាត្រា ៥៤. ការពន្យារពេលចូលនិវត្តន៍**

មន្ត្រី-បុគ្គលិកដែលដល់អាយុចូលនិវត្តន៍អាចនឹងត្រូវបានពន្យារពេលចូលនិវត្តន៍ឱ្យ០១ឆ្នាំម្តងៗ បើសិនជា :

- អាជ្ញាធរអគ្គិសនីកម្ពុជាមិនអាចរកអ្នកជំនួសបាន
- សាមីជនមានសមត្ថភាព និងបទពិសោធន៍ល្អ ព្រមទាំងនៅមានសុខភាពមាំទាំ ។

ការពន្យារពេលនេះអាចធ្វើទៅបានតាមសំណើជាបន្តបន្ទាប់របស់ការិយាល័យ នាយកដ្ឋាន នាយកប្រតិបត្តិ និងសម្រេចដោយប្រធានអាជ្ញាធរ ។

**មាត្រា ៥៥. ការកែប្រែជំពូកស្តីពីការចូលនិវត្តន៍**

គោលការណ៍ដូចមានចែងក្នុងមាត្រា ៥៣-៥៤ខាងលើនេះ នឹងត្រូវកែប្រែឡើងវិញទៅតាមច្បាប់ស្តីពីការធានារ៉ាប់រងជរាភាព ទុព្វលភាព និងមរណភាព នៅពេលដែលច្បាប់នេះត្រូវបានប្រកាសឱ្យប្រើប្រាស់ ។

## ជំពូកទី ១៤

## អវសានប្បញ្ញត្តិ

**មាត្រា ៥៦.- ការកែសម្រួលបទបញ្ជាផ្ទៃក្នុងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា**

សម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជាអាចពិនិត្យ កែសម្រួល បំពេញបន្ថែម ឬធ្វើវិសោធនកម្ម លើមាត្រាទាំងឡាយនៃបទបញ្ជាផ្ទៃក្នុងរបស់អាជ្ញាធរអគ្គិសនីកម្ពុជាបាន តែការកែសម្រួលនិងវិសោធនកម្ម នេះមិនត្រូវប៉ះពាល់សិទ្ធិរបស់អ្នកធ្វើសេវាកម្មអគ្គិសនី និងអ្នកប្រើប្រាស់អគ្គិសនីឡើយ ។

**មាត្រា ៥៧.- ប្រសិទ្ធភាពអនុវត្តន៍**

បទបញ្ជាផ្ទៃក្នុងរបស់អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវចូលជាធរមាន និងមានប្រសិទ្ធភាពអនុវត្តន៍ចាប់តាំងពីថ្ងៃចុះហត្ថលេខាប្រកាសឱ្យប្រើប្រាស់ដោយប្រធានអាជ្ញាធរ បន្ទាប់ពីការសម្រេចរបស់សម័យប្រជុំអាជ្ញាធរ ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**